សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de droit et des sciences Economoiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាបញ្ញើ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា. **ចិន សាវ៉ាត**
កញ្ញា. **ហឺយ សៀងលី**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ឫទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

គម្រោងនៃការសិក្សាស្រាវជ្រាវនេះ គឺ នាងខ្ញុំ ចិន សាវ៉ាត និង នាងខ្ញុំ ហើយ សៀងលី ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចបានខិតខំលះបង់ពេលវេលាផ្ទាល់ខ្លួនជាច្រើន និងសហការរួមគ្នាចងក្រងជាស្នាដៃមួយនេះឡើង។ តែទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវនេះ មិនអាចសម្រេចបាននោះទេប្រសិនបើគ្មានការគាំទ្រពី លោកអ្នកមានគុណដូចខាងក្រោម៖

- **លោកឪពុក អ្នកម្តាយ** របស់យើងខ្ញុំទាំងពីរដែលលោកទាំងពីរខិតខំចិញ្ចឹមបីបាច់ថែរក្សា តាំងពីតូចរហូតដល់ធំដឹងក្តីបានរៀនសូត្រចេះដឹងនេះ។ លោកទាំងពីរ មិនដែល ត្អូញត្អែរថានឿយហត់ឱ្យកូនឮម្តងណាឡើយ ដោយខ្សែកតែងតែជម្រុញ និង លើកទឹកចិត្តឱ្យខំពុះពារគ្រប់ឧបសគ្គ ដើម្បីក្លាយជាមនុស្សថ្លៃថ្នូរម្នាក់ក្នុងសង្គម។ ការលះបង់ដ៏ធំធេងរបស់លោកទាំងពីរពិតជាធ្វើឱ្យយើងទាំងពីរចងចាំជានិច្ចនិរន្តរ៍។
- **ថ្នាក់ដឹកនាំ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យនាងខ្ញុំទាំងពីរបានចូលសិក្សានៅសាកលវិទ្យាល័យនេះ និងមានភាពងាយស្រួលដល់ការសិក្សារបស់នាងខ្ញុំទាំងពីរឱ្យកាន់តែប្រសើរឡើង។
- សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ណែនាំ ពន្យល់ និងផ្តល់ជាដំបូន្មានល្អៗ ដល់នាងខ្ញុំទាំងពីរ។
- ជាពិសេស លោកសាស្ត្រាចារ្យ **ញឹក ឧុឆ្មី** ជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលផ្ទាល់ខ្លួនដ៏មានតម្លៃមក ពន្យល់ បង្ហាត់បង្ហាញ ណែនាំ និងឱ្យជាយោបល់ល្អៗដល់នាងខ្ញុំទាំងពីរ ដើម្បីរៀបចំសារណាបញ្ចប់ការសិក្សាមួយនេះឡើង។

ជាទីបញ្ចប់នេះ នាងខ្ញុំទាំងពីរសូមប្រសិទ្ធិពរជ័យជូនដល់ លោកអ្នកមានគុណទាំងអស់ខាងលើ សូមឱ្យបានប្រកបតែជោគជ័យគ្រប់ភារកិច្ចនិងសូមទទួលបាននូវ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋម នាងខ្ញុំ ចិន សារ៉ាត និង នាងខ្ញុំ ហ៊ីយ សៀងលី សូមគោរពលោកសាស្ត្រាចារ្យ ព្រមទាំងស្វា-គមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេស សិស្ស និស្សិត ជាទីរាប់អាន។

ក្នុងនាមជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រដែលទាក់ទងទៅនឹង នីតិឯកជនដែលប្រធានបទនេះគឺ "**កិច្ចសន្យាបញ្ញើ**" នេះឡើង ដោយសារតែមើលឃើញថានៅមានការកង្វះខាតនូវឯកសារជំនួយបន្ថែម សម្រាប់និស្សិតផ្នែកនីតិសាស្ត្រ និង អ្នកស្រាវជ្រាវយកទៅប្រើប្រាស់។ ហេតុនេះហើយបានជាយើងខ្ញុំទាំងពីរ បានរៀបចំសារណា ពីប្រធានបទមួយនេះឡើង ព្រមទាំងមានការគាំទ្រ និង លើកទឹកចិត្តពីសំណាក់លោកសាស្ត្រាចារ្យ **ញឹក ឧុធ្ធី** ដែលជាសាស្ត្រចារ្យ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំទាំងពីរពិតជាមាន មោទនភាព និងសប្បាយរីករាយណាស់ ដែលបានតាក់តែងនូវស្នាដៃមួយនេះឡើង បើទោះបីជានាងខ្ញុំទាំងពីរមានការលំបាកក្នុងការស្រាវជ្រាវ ការខ្វះនូវឯកសារយ៉ាងណាក្ដី ក៏នាងខ្ញុំទាំងពីរបានខិតខំរកឯកសារ ស្រាវជ្រាវ និងធ្វើការស្វែងយល់ពីប្រធានបទនេះ រហូតដល់នាងខ្ញុំទាំងពីរទទួលបានជោគ-ជ័យនៅក្នុងការសរសេរសារណាមួយនេះ។ នៅក្នុងសារណាមួយនេះ បានរៀបរាប់ពី លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ លក្ខណៈនៃកិច្ចសន្យាបញ្ញើ ( យកកម្រៃ និងមិនយកកម្រៃ )សិទ្ធិ និង ករណីយកិច្ចរបស់អ្នកផ្ញើនិងអ្នកទទួលបញ្ញើ និង ការរួចផុតពីការទទួលខុសត្រូវនៃកិច្ចសន្យាបញ្ញើ ( យកកម្រៃ និង មិនយកកម្រៃ )។ នាងខ្ញុំទាំងពីរ សង្ឃឹមថាសារណាមួយនេះ នឹងក្លាយជាឯកសារសម្រាប់ជំនួយស្មារតីដល់ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីសិក្សាស្វែងយល់ ស្រាវជ្រាវ ហើយទទួលបានចំណេះដឹងរៀងៗខ្លួនតាមការគួរ ដើម្បីចូលរួមចែករំលែក ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់ជាតិយើង។

ជាទីបញ្ចប់នាងខ្ញុំទាំងពីរ មានសេចក្ដីសោមនស្សរីករាយនឹងស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីឱ្យសារណាមួយនេះក្លាយជាឯកសារត្រឹមត្រូវពេញលេញមានអត្ថន័យ និង អត្ថប្រយោជន៍គ្រប់គ្រាន់ដល់សិស្សនិស្សិតជាទៀត។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ......... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ......... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ......... ១

៣. គោលបំណងនៃការស្រាវជ្រាវ ......... ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ......... ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ......... ២

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......... ២

**ជំពូកទី១**

**លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ**

**ផ្នែកទី១៖ ការព្រមព្រៀង** ......... ៣

**កថាភាគទី១៖ សំណើ** ......... ៣

ក. លក្ខខណ្ឌសុពលភាពនៃសំណើ ......... ៣

ក.១. សំណើត្រូវបញ្ជាក់ពីបំណងប្រាកដ ......... ៣

ក.២. សំណើត្រូវតែច្បាស់លាស់ ......... ៤

ក.៣. សំណើត្រូវឱ្យដឹងដល់អ្នកទទួលសំណើ ......... ៤

ខ. អានុភាពនៃសំណើ ......... ៤

ខ.១. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើ ......... ៤

ខ.២. សំណើមានកំណត់អំឡុងពេលសម្រាប់ស្វីការ និងការដកសំណើ ......... ៥

**កថាភាគទី២៖ ស្វីការ** ......... ៥

**កថាភាគទី៣៖ ការព្រមព្រៀងមិនត្រូវឱ្យមានវិការៈ** ......... ៦

ក. ការភាន់ច្រឡំ ......... ៦

ខ. ការឆបោក ......... ៧

គ. ព័ត៌មានមិនពិត ......... ៧

ឃ. ការរំលោភបំពានលើស្ថានភាព ......... ៨

ង. ការគម្រាមកំហែង ......... ៨

ច. អំពើកេងយកចំណេញហួសហេតុ........................................................................................៩

ឆ. បបនីយផ្លូវចិត្ត ....................................................................................................................៩

**ផ្នែកទី២៖ កម្មវត្ថុ**...................................................................................................................៩

**កថាភាគទី១៖ កម្មវត្ថុនៃកិច្ចសន្យា**...............................................................................................៩

**កថាភាគទី២៖ កម្មវត្ថុនៃកាតព្វកិច្ច**........................................................................................... ១០

**ផ្នែកទី៣៖ សមត្ថភាពគូភាគី**.................................................................................................... ១០

**កថាភាគទី១៖ សមត្ថភាពទទួលបាននូវសិទ្ធ** .................................................................................. ១០

**កថាភាគទី២៖ សមត្ថភាពខាងឆន្ទៈ**.............................................................................................. ១១

**កថាភាគទី៣៖ សមត្ថភាពក្នុងការធ្វើសកម្មភាព** ........... ......................................................................១១

## ជំពូកទី២

## កិច្ចសន្យាបញ្ញើមិនយកកម្រៃ

**ផ្នែកទី១៖ សញ្ញាណនៃកិច្ចសន្យាបញ្ញើមិនយកកម្រៃ**........................................................... ១២

**កថាភាគទី១៖ និយមន័យ** ......................................................................................................១២

**កថាភាគទី២៖ លក្ខណៈនៃកិច្ចសន្យាបញ្ញើមិនយកកម្រៃ** ..........................................................១២

**ផ្នែកទី២៖ សិទ្ធិ និងករណីយរបស់អ្នកផ្ញើ**.................................................................................. ១៤

**កថាភាគទី១៖ សិទ្ធិរបស់អ្នកផ្ញើ** ............................................................................................. ១៤

ក. ការទាមទារវត្ថុបញ្ញើ................................................................................................... ១៤

ខ. ការដកការព្រមព្រៀងចំពោះបញ្ញើនៅពេលអនាគត............................................................ ១៥

គ. ការទាមទារសំណង ....................................................................................................... ១៥

**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកផ្ញើ** ..................................................................................... ១៥

ក. ទទួលបន្ទុកសោហ៊ុយនៃការសងបញ្ញើ.............................................................................. ១៥

ខ. សោហ៊ុយសម្រាប់ការរក្សាទុក .......................................................................................... ១៦

**ផ្នែកទី៣៖ សិទ្ធិ និង ករណីយកិច្ចអ្នកទទួលបញ្ញើ**....................................................................... ១៦

**កថាភាគទី១៖ សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ**........................................................................ ១៦

**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ** .........................................................................១៧

ក. ករណីយកិច្ចថែរក្សាវត្ថុបញ្ញើ............................................................................១៧
ខ. ការរក្សាទុកដោយខ្លួនឯង..................................................................................១៧
គ. ករណីយកិច្ចជូនដំណឹង......................................................................................១៧
ឃ. ករណីយកិច្ចសងវត្ថុដែលផ្ញើ................................................................................១៨
ង. ការសងការខូចខាត ...........................................................................................១៨
**កថាភាគទី៣៖ ការរួចផុតពីការទទួលខុសត្រូវអ្នកទទួលបញ្ញើ**........................................១៩

## ជំពូកទី៣

## កិច្ចសន្យាបញ្ញើយកកម្រៃ

**ផ្នែកទី១៖ សញ្ញាណនៃកិច្ចសន្យាបញ្ញើយកកម្រៃ**............................................................២១
**កថាភាគទី១៖ និយមន័យ** ...........................................................................................២១
**កថាភាគទី២៖ លក្ខណៈនៃកិច្ចសន្យាបញ្ញើយកកម្រៃ** ........................................................២២
**ផ្នែកទី២៖ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកផ្ញើ** ............................................................... ២៣
**កថាភាគទី១៖ សិទ្ធិរបស់អ្នកផ្ញើ**.................................................................................. ២៣
ក. សិទ្ធិទាមទារវត្ថុបញ្ញើ ...................................................................................... ២៣
ខ. សិទ្ធិទាមទារសំណងនៃការខូចខាត....................................................................... ២៣
**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកផ្ញើ** .........................................................................២៤
ក. រាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើ..............................................................២៤
ខ.បង់កម្រៃសេវាវត្ថុបញ្ញើ .........................................................................................២៤
**ផ្នែកទី៣៖ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ**......................................................២៤
**កថាភាគទី១៖ សិទ្ធិរបស់អ្នកទទួលបញ្ញើ**.........................................................................២៥
ក. សិទ្ធិទាមទារកម្រៃនៃសេវាបញ្ញើ............................................................................២៥
ខ. សិទ្ធិសងវត្ថុបញ្ញើនៅពេលណាក៏បាន(ករណីពុំមានកំណត់ពេលសង) ...............................២៥
គ. សិទ្ធិទាមទារសំណងដែលបណ្តាលមកពីវត្ថុបញ្ញើដែលមិនមែនជាកំហុសរបស់ខ្លួន ..............២៦
ឃ. សិទ្ធិឃាត់ទុក ....................................................................................................២៦
**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ**...............................................................២៦

ក. រក្សាទុកវត្ថុបញ្ញើ......................................................................................................២៦
ខ. សងការខូចខាត.........................................................................................................២៦
គ. ករណីយកិច្ចជូនដំណឹង ..............................................................................................២៧
ឃ. ករណីយកិច្ចសងវត្ថុដដែល(ដែលបានទទួល)...................................................................២៧
ង. សងវត្ថុដែលបានធ្វើឧបាទេសកម្ម....................................................................................២៧
ច. ប្រគល់ផល និង ចំណូលពីវត្ថុបញ្ញើទៅអ្នកផ្ញើ....................................................................២៨
ឆ. សោហ៊ុយនៃការសងវត្ថុបញ្ញើ........................................................................................២៨
**កថាភាគទី៣៖ ការរួចផុតពីការទទួលខុសត្រូវអ្នកទទួលបញ្ញើ**.........................................២៩
**សេចក្តីសន្និដ្ឋាន** ..........................................................................................................៣១
**អនុសាសន៍** ................................................................................................................ ៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីពេលដែលរបបកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ បុគ្គលម្នាក់ៗតែងខិតខំរកទ្រព្យសម្បត្តិឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ។

ការរក្សាទុកទ្រព្យសម្បត្តិដែលរកបានមកហើយឱ្យបានគង់វង្ស គឺជាកិច្ចការចាំបាច់ដែលត្រូវធ្វើ ពីព្រោះថាវាគឺជាការខាតបង់មួយដ៏ធ្ងន់ធ្ងរ ប្រសិនបើទ្រព្យសម្បត្តិដែលរកបានមកហើយនោះត្រូវខូចខាតឬបាត់បង់ទៅវិញដោយសារតែកង្វះការរក្សាទុកឱ្យបានត្រឹមត្រូវ។

ដើម្បីរក្សាទុកវត្ថុមួយអោយបានគង់វង្ស គឺទាមទារឱ្យមានការប្រុងប្រយត្ន័ពីបុគ្គលដែលមានភារកិច្ចរក្សាទុកវត្ថុ និង មានទីកន្លែងដែលមានសុវត្ថិភាពសម្រាប់រក្សាទុកវត្ថុនោះ។ ជាទូទៅកម្មសិទ្ធិករច្រើនតែរក្សាទុកទ្រព្យដោយខ្លួនឯងផ្ទាល់ និង មានទីកន្លែងដែលមានសុវត្ថិភាពសម្រាប់រក្សាទុកទ្រព្យនោះដោយខ្លួនឯងផងដែរ។ ទោះជាយ៉ាងណា ក៏មានករណីច្រើនដែលកម្មសិទ្ធិករ មិនអាចរក្សាទុក ឬ មិនចង់រក្សាទុកទ្រព្យដោយខ្លួនឯង ដោយហេតុផលណាមួយចំនួន ជួនកាលដោយសារតែ កម្មសិទ្ធិករត្រូវការធ្វើដំណើរទៅឆ្ងាយមួយរយៈ ជួនកាលដោយសារតែកម្មសិទ្ធិករ ពុំមានទីកន្លែងដែលមានសុវត្ថិភាពគ្រប់គ្រាន់សម្រាប់ រក្សាទុកទ្រព្យ និងជួនកាលកម្ម-សិទ្ធិករខ្លួនឯងមិនចង់ចំណាយពេលច្រើនក្នុងការរក្សាទុកទ្រព្យ ហើយជួនកាលដោយសារតែកម្មសិទ្ធិករមិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកទ្រព្យដោយខ្លួនឯង។ ដោយសារកាលៈទេសៈ និងហេតុផលទាំងនេះកិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងជារៀងរាល់ថ្ងៃ។

ទន្ទឹមនឹងនេះ ការបង្កើតឡើងនូវកិច្ចសន្យាបញ្ញើ វិវាទអំពីទំនាក់ទំនងស្តីពីបញ្ញើក៏បានកើតឡើងជាញឹកញាប់ផងដែរ។ ហេតុដូច្នេះ ដើម្បីសម្រួលដល់ការបង្កើតកិច្ចសន្យាបញ្ញើ និង ដើម្បីជាមូលដ្ឋានសម្រាប់ដោះស្រាយវិវាទអំពីបញ្ញើឱ្យបានត្រឹមត្រូវនិង មានប្រសិទ្ធិភាពនោះបញ្ញត្តិស្តីពី បញ្ញើត្រូវបានតាក់តែងឡើង នៅក្នុងគន្ថីទី៥ ជំពូកទី១០ ចាប់ពីមាត្រា ៦៦៩ ដល់ មាត្រា ៦៩៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្រមរដ្ឋប្បវេណីក៏បានឱ្យនិយមន័យនៃ បញ្ញើយ៉ាងច្បាស់លាស់នៅក្នុងមាត្រា ៦៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

បញ្ញើ សំដៅដល់កិច្ចសន្យាដែលភាគីម្ខាង ជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះទៅឱ្យអ្នកផ្ញើវិញ។ ហើយដើម្បីឱ្យកាន់តែយល់ច្បាស់ពីកិច្ចសន្យាបញ្ញើ យើងនឹងធ្វើការបកស្រាយជាបន្តបន្ទាប់។

## ២ . ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអ្វីទៅជាបញ្ញើ ? តើបញ្ញើត្រូវបានបង្កើតឡើងនៅពេលណា ? តើភាគីនៃបញ្ញើមានសិទ្ធិ ករណីយកិច្ច និងការរួចផុតពីការទទួលខុសត្រូវក្នុងករណីអ្វីខ្លះ ?

## ៣ . គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទនេះគឺ ផ្តោតសំខាន់ទៅលើ សិទ្ធិ និង ករណីយកិច្ច របស់អ្នកផ្ញើ និងអ្នកទទួលបញ្ញើដែលមានក្នុងកិច្ចសន្យាបញ្ញើ ( យកកម្រៃ និង មិនយកកម្រៃ )។ ម្យ៉ាងទៀតចង់ចែករំលែកនូវចំណេះដឹង ដែលបានសិក្សាអស់រយៈពេលបួនឆ្នាំនេះ ទៅដល់សិស្សនិស្សិតជំនាន់ក្រោយ និងមិត្តៗអ្នកអានទាំងអស់។

## ៤ . ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដោយប្រធានបទនេះ ទាក់ទងទៅនិងនីតិឯកជន ដែលពាក់ព័ន្ធទៅនិងកិច្ចសន្យាបញ្ញើ ដែលមានចែងក្នុងមាត្រា៦៦៩ ដល់ មាត្រា៦៩១នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាធរមាន ដូច្នេះយើងខ្ញុំសូមធ្វើការសិក្សាស្រាវជ្រាវត្រឹមតែមាត្រាដែលបានកំណត់ខាងលើលើកលែងតែវិសុណ្ឌាប័នយើងខ្ញុំសូមមិនធ្វើការបកស្រាយទេ។

## ៥ . សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងសារៈសំខាន់នៃការស្រាវជ្រាវប្រធានបទនេះគឺៈ

- ដើម្បីជាចំណេះដឹងសម្រាប់ សិស្សនិស្សិត មិត្តៗអ្នកអាន និងប្រជាជនដែលរស់នៅប្រទេសកម្ពុជា ឱ្យកាន់តែយល់ច្បាស់ជាងមុន។
- ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍វិស័យ ប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់មានភាពប្រសើរឡើងជាងមុន។
- ដើម្បីទុកជាឯកសារនៅក្នុងបណ្ណាល័យ ដល់សិស្សានុសិស្ស និស្សិតជំនាន់ក្រោយ មិត្តៗអ្នកអាន ធ្វើការសិក្សាស្រាវជ្រាវបន្ថែម។

## ៦ . រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទ " កិច្ចសន្យាបញ្ញើ " យើងនឹងធ្វើការសិក្សាទៅលើ បី ជំពូកគឺៈ

ជំពូកទី១ៈ លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ

ជំពូកទី២ៈ កិច្ចសន្យាបញ្ញើមិនយកកម្រៃ

ជំពូកទី៣ៈ កិច្ចសន្យាបញ្ញើយកកម្រៃ

ដូច្នេះ យើងខ្ញុំនឹងធ្វើការសិក្សាទៅលើ បី ជំពូកនេះដែលមាននៅក្នុងទំព័រខាងមុខជាបន្តបន្ទាប់។

# ជំពូកទី១
# លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ

# ជំពូកទី១
# លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ញើ

## ផ្នែកទី១៖ ការព្រមព្រៀង

ជាគោលការណ៍កិច្ចសន្យា ត្រូវបានបង្កើតឡើងតាមរយៈការព្រមព្រៀង។ ហើយវាមានអានុភាពនៅពេលដែលសំណើជួបជាមួយស្វីការ។

**ឧទាហរណ៍៖** A ចង់ផ្ញើកាបូបនិង B ហើយ B យល់ព្រមតាមសំណើរបស់ A។ នេះបញ្ជាក់ពីសំណើជួបជាមួយស្វីការ បង្កើតជាកិច្ចសន្យាបញ្ញើ។

### កថាភាគទី១៖ សំណើ

**សំណើ** គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹង ចំណងគត្តិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[1]។ នៅក្នុងកិច្ចសន្យាបញ្ញើ អ្នកផ្ញើ មានឆន្ទៈផ្ទេរបន្ទុកហានិភ័យទៅអ្នកទទួលបញ្ញើ ដោយការផ្ទេរការកាន់កាប់។

សំណើត្រូវតែមានអានុភាពនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត។ បើទោះជាភាគីម្ខាងនោះមិនទាន់បានអានក៏ដោយ ឱ្យតែបានទៅដល់ប្រអប់សំបុត្រគឺ ចាត់ទុកថាភាគីម្ខាងនោះបានទទួលសំណើរួចហើយ ម្យ៉ាងទៀតបើ ទោះបីជាអ្នកផ្ទះដែលរស់នៅជាមួយអ្នកទទួលសំណើបានទទួលក៏គេចាត់ទុកថាភាគីម្ខាងនោះបានទទួលសំណើដែរ។

#### ក . លក្ខខណ្ឌសុពលភាពនៃសំណើ

##### ក.១ . សំណើត្រូវបញ្ជាក់ពីចំណងប្រាកដ

សំណើត្រូវតែបង្ហាញឱ្យច្បាស់លាស់ថា អ្នកស្នើមានបំណងចង់ធ្វើកិច្ចសន្យាពិតមែន។ មិនមែនសំណើនោះធ្វើឡើងដោយសម្តីលេងសើច មិនច្បាស់លាស់ មិនមានគោលដៅពិតប្រាកដ ឬក្នុងពេលភ័យខ្លាចនោះវាមិនអាចបង្កើតសំណើតាមផ្លូវច្បាប់សម្រាប់ភាគីម្ខាងទៀតក្នុងការធ្វើស្វីការឡើយ។ ហើយវាក៏មិនអាចបង្កើតកិច្ចសន្យាចងកាតព្វកិច្ចបានដែរ។

**ឧទាហរណ៍ទី១៖** លោក A បានដាក់សំណើទៅលោក B ថាគាត់ត្រូវផ្ញើឡានដើម្បីឱ្យ B រក្សាទុកឡានខ្លួនដោយខ្លួនត្រូវចេញទៅបរទេស។

**ឧទាហរណ៍ទី២៖** បើលោក A បានដាក់សំណើទៅលោក B ថាគាត់អាចនឹងផ្ញើឡានដើម្បីឱ្យ B រក្សាទុកឡានខ្លួនដោយខ្លួនត្រូវចេញទៅបរទេស។ ក្នុងន័យនេះមានន័យថា លោក A បានដាក់សំណើមែន តែមិនប្រាកដថាគាត់មានបំណងផ្ញើឡានឱ្យលោកB ឬអត់ទេព្រោះគាត់ប្រើពាក្យថាអាចនឹងផ្ញើដែលបញ្ជាក់ថាវាមិនច្បាស់លាស់។

[1] មាត្រា ៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ក.២. សំណើត្រូវតែច្បាស់លាស់**

ដើម្បីឱ្យសំណើមួយទៅជាសំណើច្បាស់លាស់គ្រប់គ្រាន់ទៅបាន លុះត្រាតែសំណើនោះច្បាស់លាស់អំពីខ្លឹមសារ មានលិខិតលាយល័ក្ខអក្សរ និងគោលបំណងពិតប្រាកដ។

**ឧទាហរណ៍ទី១៖** លោក "ក" បានដាក់សំណើដោយសរសេរជាលាយល័ក្ខអក្សរទៅលោក "ខ" ថាគាត់យកឡានទៅផ្ញើនៅកន្លែងផ្ញើឡានរបស់លោក "ខ" ក្នុងតម្លៃ ២០$ក្នុងមួយខែ ដោយបញ្ជាក់ពីម៉ាក និងប្រភេទឡានច្បាស់លាស់។ បន្ទាប់មកលោក "ខ" បានទទួលសំណើរួចក៏ឆ្លើយយល់ព្រមទទួលបញ្ញើឡានរបស់ លោក "ក"។ នៅក្នុងនេះបានបញ្ជាក់ច្បាស់ថាលោក "ក" មានបំណងចង់ផ្ញើឡានឲ្យទៅលោក "ខ"។

**ឧទាហរណ៍ទី២៖** លោក "ក" បានដាក់សំណើដោយសរសេរជាលាយល័ក្ខអក្សរទៅលោក "ខ" ថាគាត់យកឡានទៅផ្ញើនៅកន្លែងផ្ញើឡានរបស់លោក "ខ" ដោយមិនបានបញ្ជាក់ពីម៉ាក ប្រភេទឡាន និងរយៈពេលដែលផ្ញើអោយបានច្បាស់លាស់ឡើយ។ ដោយសារសំណើរបស់លោក "ក" មិនមានភាពច្បាស់លាស់ ដូចនេះវាមិនមានអានុភាពជាសំណើឡើយ។

**ក.៣. សំណើត្រូវឱ្យដឹងដល់អ្នកទទួលសំណើ**

បើអ្នកស្នើមិនបានផ្ញើសំណើដល់ភាគីម្ខាងទៀត ហើយភាគីម្ខាងនោះមិនបានទទួលសំណើក៏មិនអាចបង្កើតជាកិច្ចសន្យាជាប់កាតព្វកិច្ចជាមួយ អ្នកស្នើនោះបានដែរ។ ប៉ុន្តែបើក្នុងករណីដែលអ្នកស្នើ ឬអ្នកទទួលសំណើបានប្រគល់សិទ្ធិអំណាចទៅអ្នកផ្សេងជាតំណាងខ្លួនដើម្បីផ្ញើសំណើឬទទួលសំណើជំនួសបាន។ សំណើមានអានុភាពនៅពេលដែលសំណើនោះ បានដល់ភាគីម្ខាងទៀត តែបើភាគីម្ខាងនោះមិនបានទទួលសំណើទេ នោះសំណើក៏មិនមានអានុភាពបានដែរ។

**ឧទាហរណ៍ទី១៖** A បានដាក់សំណើទៅ B ថៃដន្យ B មិនបាននៅផ្ទះ តែប្រពន្ធរបស់ B គឺគាត់នៅផ្ទះ ហើយបានទទួលសំណើនេះជំនួសប្តីរបស់គាត់។ ក្នុងករណីនេះគេចាត់ទុកថា B បានទទួលសំណើដោយប្រពន្ធរបស់គាត់ជាអ្នកមកទទួលជំនួស។

**ឧទាហរណ៍ទី២៖** បើ A និងប្រពន្ធមិននៅផ្ទះទាំងពីរ ហើយក៏មិនមានអ្នកណាផ្សេងទៀតនៅផ្ទះដែរ។ ក្នុងន័យនេះគឺសំណើមិនមានអានុភាពទេ ព្រោះមិនអាចបញ្ជាក់ថាសំណើនោះបានដល់ហើយ ឬក៏នៅ។

**ខ.អានុភាពនៃសំណើ**

ដើម្បីឱ្យសំណើមានអានុភាពលុះត្រាតែ៖

**ខ.១. សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើ**

សំណើគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការ គឺជាសំណើមួយដែលភាគីអ្នកស្នើ បានដាក់សំណើរបស់ខ្លួន ទៅភាគីម្ខាងទៀតដោយមិនបានបញ្ជាក់អំពី អំឡុងពេលសម្រាប់ធ្វើស្ទីការ នៅពេលណាមួយជាក់លាក់ដូចជា ករណីដែលគូភាគីមិនបានប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់និង ការទាក់ទងគ្នាដោយប្រយោល។

ចំពោះសំណើ ដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ ស្ទីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលឆ្លើយតបភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លា-

មៗទេសំណើនោះត្រូវបាត់បង់អានុភាព។

ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិនបាននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។

ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ[2]។

**ឧទាហរណ៍ ៖** លោក "ក" និង កញ្ញា "ខ" កំពុងពិភាក្សាមេរៀននៅសាលា លោក "ក" បានដាក់សំណើទៅ កញ្ញា "ខ" ថាគាត់ផ្ញើកុំព្យូទ័រដោយផ្តល់កម្រៃឱ្យកញ្ញា "ខ"។ កញ្ញា "ខ" មិនទាន់តបផង លោក "ក" ថាមិនផ្ញើទេ លែងផ្ញើហើយ ហើយក៏យកកុំព្យូទ័រដើរទៅបាត់។

**ខ.២. សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និងការដកសំណើ**

សំណើមានកំណត់អំឡុងពេលសម្រាប់ស្ទីការ គឺជាសំណើមួយដែលភាគីអ្នកស្នើបានដាក់សំណើរបស់ខ្លួន ទៅភាគីម្ខាងទៀតដោយបានបញ្ជាក់អំឡុងពេលសម្រាប់ធ្វើស្ទីការជាក់លាក់។

សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ។ អំឡុងពេលសម្រាប់ស្ទីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង។

សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្ទីការ មិនអាចដកវិញបានទេ។

ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្ទីការ ក្នុងអំឡុងពេលដែលបានកំណត់នៅចំណុចទី១ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ស្ទីការ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានមកដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្ទីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ[3]។

**ឧទាហរណ៍ ៖** លោក "ក" បានដាក់សំណើទៅកញ្ញា "ខ" ថាផ្ញើម៉ូតូនៅឃ្លាំងផ្ញើម៉ូតូរបស់ កញ្ញា "ខ" ដោយយកកម្រៃ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ព្រោះ លោក "ក" គាត់ត្រូវទៅខេត្តនៅ ថ្ងៃហ្នឹង។ ដោយគាត់ ( លោក "ក" )បានប្រាប់ឱ្យកញ្ញា "ខ" ឆ្លើយតបនឹងសំណើគាត់ឱ្យបានមុនថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។ ក្នុងករណីនេះបើមិនទាន់ផុតអំឡុងពេលសម្រាប់ស្ទីការ លោក "ក" មិនអាចដកសំណើវិញបានទេ។

## កថាភាគទី២ ៖ ស្ទីការ

**ស្ទីការ** គឺការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[4]។ កិច្ចសន្យាបញ្ញើ អ្នកទទួលបញ្ញើមានឆន្ទៈ ទទួលយកបន្ទុកហានិភ័យដោយរក្សាទុកវត្ថុបញ្ញើ ដើម្បីប្រយោជន៍របស់អ្នកផ្ញើ។ ស្ទីការត្រូវឆ្លើយតបទាំងស្រុងទៅលើសំណើទៅនឹងសំណើដើម ដោយមិនត្រូវមានលក្ខខណ្ឌលើសំណើ ឬបន្ថែម កែប្រែលើសំណើឡើយ។ ប៉ុន្តែស្ទីការអាចមានការកែប្រែបន្ថែមបានក្នុងករណី៖

[2] មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[3] មាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[4] មាត្រា ៣៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់លក្ខខណ្ឌលើសំណើ ឬកែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ។
- ប្រសិនបើលក្ខខណ្ឌ ឬការកែប្រែដែលភ្ជាប់ជាមួយនឹង ស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ[5]។

**ឧទាហរណ៍ ៖** លោក "ក" បានដាក់សំណើទៅកញ្ញា "ខ" ថាផ្ញើម៉ូតូនៅឃ្លាំងផ្ញើម៉ូតូរបស់កញ្ញា "ខ" ដោយយកកម្រៃនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ព្រោះ លោក "ក" គាត់ត្រូវទៅខេត្តនៅថ្ងៃហ្នឹង។ កញ្ញា "ខ" ឆ្លើយតបទៅលោក "ក" ថាយល់ព្រម តែត្រូវផ្ញើត្រឹមតែ ២ថ្ងៃប៉ុណ្ណោះ។ ស្ទីការនេះមានអានុភាពជាសំណើថ្មី។ ប្រសិនបើលោក "ក" មិនតវ៉ាភ្លាមទេមានន័យថាយល់ព្រមនោះ សំណើថ្មីរបស់កញ្ញា "ខ" មានអានុភាព។

**កថាភាគទី៣៖ កិច្ចសន្យាមិនត្រូវឱ្យមានវិការៈ**

កិច្ចសន្យាគឺមិនត្រូវឱ្យមានវិការៈ ព្រោះបើមានវិការៈគឺ កិច្ចសន្យាមិនមានអានុភាពឡើយ។ ហេតុនេះហើយកិច្ចសន្យាគឺ មិនឱ្យមានវិការៈដូចខាងក្រោម៖

**ក. ការភាន់ច្រឡំ**

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពី ការភាន់ច្រឡំនេះភាគីដែលបានភាន់ច្រឡំ អាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងបានស្ថិតក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ក្នុងករណីដែល ភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ច-សន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពី ការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

[5] មាត្រា ៣៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំមិនអាចអះអាងនូវការលុបចោលចំពោះតតិ-យជននោះបានឡើយ[6]។

**ឧទាហរណ៍៖** លោក "ក" បានដាក់សំណើដោយសរសេរជាលាយល័ក្ខអក្សរទៅលោក "ខ" ថាគាត់យកឡានទៅផ្ញើនៅកន្លែងផ្ញើឡានរបស់លោក "ខ" ក្នុងតម្លៃ១០$ក្នុងមួយខែ ដោយមិនបានបញ្ជាក់ពីម៉ាក និងប្រភេទឡានច្បាស់លាស់។ ដោយលោក "ខ" បានគិតថាឡាននោះជាប្រភេទឡានធម្មតា (CAMARY BALEN) គាត់បានទទួលសំណើរួចក៏ឆ្លើយយល់ព្រមទទួលបញ្ញើឡានរបស់លោក "ក"។ បន្ទាប់មកលោក "ក" បានយកឡានមកផ្ញើ ប៉ុន្តែឡាននោះជាប្រភេទឡានដែលមានតម្លៃថ្លៃ (LAMBORGHINI)។ លោក "ខ" គ្រាន់តែបានឃើញឡានភ្លាម គាត់មិនចង់ទទួលបញ្ញើឡាននេះឡើយ។ ក្នុងករណីនេះលោក "ខ" អាចលុបចោលកិច្ចសន្យាបញ្ញើនេះបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈដោយការភាន់ច្រឡំ។

**ខ. ការឆបោក**

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែល ភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹង ឬអាចដឹងអំពីការឆបោកនោះ។

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ[7]។

**ឧទាហរណ៍៖** លោក "ក" បាននិយាយជាមួយលោក "ខ" ថាគាត់បានបើកកន្លែងទទួលបញ្ញើ ហើយបាននិយាយបញ្ចុះបញ្ចូលអោយ "ខ" ផ្ញើទំនិញនៅនិងកន្លែងរបស់ខ្លួនដោយបញ្ចុះតម្លៃ ពេលលោក "ខ" ឮបែបនេះបានយល់ព្រមចុះកិច្ចសន្យាបញ្ញើនាពេលអនាគត។ ក្រោយមក លោក "ខ" បានដឹងថាលោក "ក" មិនបានបើកកន្លែងទទួលបញ្ញើនោះទេ គឺគាត់បានបោកគេច្រើនមក តែនៅកន្លែងខុសៗគ្នា។ ក្នុងករណីនេះលោក "ខ" អាចលុបចោលកិច្ចសន្យាបញ្ញើនេះបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈដោយការឆបោក។

**គ. ព័ត៌មានមិនពិត**

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីនោះខុសពី ការពិតហើយភាគីម្ខាងទៀតបាន

[6] មាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[7] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិតប៉ុន្តែ ប្រសិនបើភាគីដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមាន វិការៈ។

ចំណុចខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការខូចខាតពីបុគ្គល ដែលបានបង្ហាញឆន្ទៈមិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស។

ការលុបចោលនូវកិច្ចសន្យា ដោយព័ត៌មានមិនពិតក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាព នៃការលុបចោលចំពោះតតិយជននោះបានឡើយ[8]។

**ឧទាហរណ៍៖** លោក "ក" បាននិយាយអួតពីកន្លែងផ្ញើម៉ូតូរបស់ខ្លួនទៅកាន់លោក "ខ" ថាកន្លែងរបស់ខ្លួន មានសុវត្ថិភាពនិងតម្លៃសមរម្យ ទាំងដឹងហើយថាតាមពិតទៅកន្លែងរបស់គាត់គ្មានសុវត្ថិភាពហើយតម្លៃថ្លៃជាង គេទៀត។

**ឃ. ការរំលោភបំពានលើស្ថានភាព**

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

ការលុបចោលនូវកិច្ចសន្យាដោយយោងតាមចំណុចខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែល ជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ[9]។

**ឧទាហរណ៍ ៖** លោក "ក" បានយកឡានទៅផ្ញើនៅឃ្លាំងរបស់លោក "ខ" ដោយនិយាយថាបើមិនព្រម ទទួលបញ្ញើទេ គាត់ ( លោក "ក" ) ប្រាកដជាតម្លើងថ្លៃការប្រាក់ ដែលលោក "ខ" បានខ្ចីពីគាត់។

**ង. ការគម្រាមកំហែង**

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់ តតិយជនអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[10]។

**ឧទាហរណ៍ ៖** លោក "ក" បានដាក់សំណើទៅលោក "ខ" ថាគាត់យកឡានទៅផ្ញើនៅកន្លែងផ្ញើឡាន របស់ លោក "ខ" តែលោក "ខ" បានបដិសេធមិនព្រមទទួលបញ្ញើរបស់ លោក "ក" ឡើយ។ លោក "ក" បាន

[8] មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[9] មាត្រា ៣៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[10] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គម្រាមថាបើលោក "ខ" មិនព្រមទទួលបញ្ញើទេលោក "ក" ទៅដុតឃ្លាំងទទួលបញ្ញើរបស់លោក "ខ" ដោយមានការភ័យខ្លាចលោក "ខ" ក៏ព្រមទទួលបញ្ញើ។

**ច. អំពើកេងយកចំណេញហួសហេតុ**

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះភាគីម្ខាងទៀតនោះ អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ[11]។

**ឧទាហរណ៍៖** លោក "ក" ជិះម៉ូតូទៅផ្សារ បន្ទាប់មកគាត់បានផ្ញើម៉ូតូនៅកន្លែងផ្ញើម៉ូតូជិតផ្សារ ( បញ្ញើ-យកកម្រៃ ) ក្រោយពីគាត់ចេញពីផ្សារបានទៅយកម៉ូតូ បន្ទាប់មកអ្នកទទួលបញ្ញើនោះឃើញថាលោក "ក" ជាមនុស្សល្ងង់ដែលជាហេតុធ្វើឱ្យ អ្នកទទួលបញ្ញើទាមទារប្រាក់លើសពីតម្លៃ ដែលធ្លាប់ផ្ញើរាល់ដង ដែលតម្លៃផ្ញើរាល់ដងត្រឹមតែ ១០០០រៀល តែគាត់ ( អ្នកទទួលបញ្ញើ ) ទាមទារដល់ទៅ ១០០០០រៀល។ ក្នុងករណីនេះលោក "ក" អាចលុបចោលកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈ។

**ឆ. ចំបនីយផ្លូវចិត្ត**

ប្រសិនបើ កិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរារាំងនូវអានុភាពឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថា ការបង្ហាញឆន្ទៈនោះខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន[12]។

**ឧទាហរណ៍ ៖** A កំពុងលង់ទឹកខណៈពេលដែល B បានដើរមកឃើញ A បានស្រែកឱ្យ B ជួយប៉ុន្តែB បាននិយាយថាខ្លួននិងព្រមជួយលុះត្រាតែ A យល់ព្រមថាយកឡានទៅផ្ញើនៅតែនិងឃ្លាំងរបស់ខ្លួន ដើម្បីរួចផុតពីសេចក្តីស្លាប់ A ក៏បានឆ្លើយយល់ព្រម។ ក្នុងករណីនេះបញ្ជាក់ថា A គ្មានឆន្ទៈក្នុងការទទួលយកសំណើរបស់ B ទេ។ ដូចនេះ A អាចបដិសេធការអនុវត្តកិច្ចសន្យាបាន។

## ផ្នែកទី២ ៖ កម្មវត្ថុ

កម្មវត្ថុក្នុងកិច្ចសន្យាមាន ៖

### កថាភាគទី១ ៖ កម្មវត្ថុនៃកិច្ចសន្យា

ជាធម្មតាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើជាចលនវត្ថុ ចំពោះអចលនវត្ថុវិញដែលត្រូវបានផ្ញើ វាមិនគ្រាន់តែត្រូវបាន គេរក្សាទុកប៉ុណ្ណោះទេ គឺវាត្រូវបានគេគ្រប់គ្រងផងដែរ ( **ឧទាហរណ៍៖** ការប្រមូលថ្លៃឈ្នួលនៃភតិសន្យា

[11] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អចលនវត្ថុ ) ហេតុដូច្នេះ ជាទូទៅ វាត្រូវបានគេបកស្រាយថាជាកិច្ចសន្យាអាណត្តិច្រើនជាងបញ្ញើ។

" ប្រាក់ " ក៏អាចក្លាយជាកម្មវត្ថុនៃបញ្ញើបានដែរ ប្រសិនបើប្រាក់នោះត្រូវបានរក្សាទុក ដោយការដាក់ក្នុងស្រោមសំបុត្រ ឬ មានការវេចខ្ចប់។ ប៉ុន្តែប្រសិនបើប្រាក់មិនត្រូវបានដាក់ក្នុងស្រោមសំបុត្រទេ កិច្ចសន្យានេះជាកិច្ចសន្យាបញ្ញើបរិភោគ។

មនុស្សមិនអាចក្លាយជាកម្មវត្ថុនៃបញ្ញើទេ។ ករណីដែលកូនជាអនីតិជន ជាអាទិ៍ ត្រូវបានយកទៅផ្ញើនឹងសាច់ញាតិ ឬ អ្នកជិតខាងឱ្យជួយមើលថែរក្សាខណៈពេលដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានធុរៈមិនមែនជាកិច្ចសន្យាបញ្ញើទេ ។ ក្នុងករណីនេះអាចបកស្រាយថាជាកិច្ចសន្យាអាណត្តិ។

សិទ្ធិលើបំណុល ដែលមានលិខិត ឬ ឯកសារបញ្ជាក់ ( ឧបករណ៍ដែលអាចជួញដូរបាន ) ក៏អាចក្លាយជាកម្មវត្ថុនៃបញ្ញើបានដែរ។

**ឧទាហរណ៍៖** ប្រព័ន្ធការពាររក្សាទុកបញ្ញើភាគហ៊ុន របស់វិនិយោគិន។

ម្យ៉ាងទៀតកម្មវត្ថុនៃកិច្ចសន្យាត្រូវតែស្របច្បាប់ មានរបៀបរៀបរយសាធារណៈឬបវេណីល្អ និងអាចអនុវត្តបាន។ ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យា ផ្ទុយនឹងច្បាប់ មិនសមស្របនិងរបៀបរៀបរយសាធារណៈឬបវេណីល្អ នោះកិច្ចសន្យាត្រូវមោឃភាពហើយមិនអាចដាក់ឱ្យអនុវត្តបានឡើយ។

**កថាភាគទី២៖ កម្មវត្ថុនៃកាតព្វកិច្ច**

កម្មវត្ថុនៃកាតព្វកិច្ច សំដៅលើតាវកាលិករបស់ភាគី ឬរបស់អ្វីមួយដែលគូភាគីត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកដូចជា ត្រូវបង់ប្រាក់ក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ ការរក្សាទុកវត្ថុបញ្ញើតាមការសន្យា។ល។

**ផ្នែកទី៣៖ សមត្ថភាពគូភាគី**

សមត្ថភាពរបស់គូភាគីក្នុងកិច្ចសន្យាមាន ៖

**កថាភាគទី១៖ សមត្ថភាពទទួលបាននូវសិទ្ធិ**

រូបវន្តបុគ្គលគ្រប់រូបមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច[13]។ គ្រប់រូបវន្តបុគ្គលទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា គឺអាចទទួលបាននូវសិទ្ធិដូចៗគ្នាមិនថាជនជាតិខ្មែរឬបរទេសដែលមករស់នៅកម្ពុជាទេគឺមានសមត្ថភាពទទួលបានសិទ្ធិដូចគ្នា ប៉ុន្តែ ជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណី ដែលមានបញ្ញត្តិផ្សេងនៅក្នុង ច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៤៤ "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី" ហេតុនេះហើយជនបរទេសមិនអាចទទួលបាននូវសិទ្ធិជាម្ចាស់ដីធ្លី

[13] មាត្រា ៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បានទេប៉ុន្តែដើម្បីសម្រួលដល់ ការវិនិយោគទុនរបស់បរទេសលើទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាទៅលើវិស័យសំណង់ស្របពេលដែលទីផ្សារអចលនវត្ថុ បច្ចុប្បន្នកំពុងរីកចម្រើនទៅមុខនោះ កម្ពុជាបានផ្តល់នូវសិទ្ធិកាន់កាប់លើអគារសហកម្មសិទ្ធិមួយចំនួនដល់ជនបរទេស ដូចជាជនបរទេសមានសិទ្ធិលើ ចំណែកឯកជននៃអាគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ ដោយមិនអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិលើជាន់ផ្ទាល់ដីនិងជាន់ក្រោមដីឡើយ។

**កថាភាគទី២ ៖ សមត្ថភាពខាងឆន្ទៈ**

**សមត្ថភាពខាងឆន្ទៈ** ជាសកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹងនិងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ម្យ៉ាងទៀត "សកម្មភាព" ក្នុងពេលនេះមានន័យថា ជាកិច្ចសន្យា និងសកម្មភាពឯកតោភាគី។ តាមគោលការណ៍ស្វ័យភាពបុគ្គលឯកជន គឺបុគ្គលអាចបង្កើតទំនាក់ទំនងគតិយុត្តរបស់ខ្លួន តាមរយៈឆន្ទៈសេរីរបស់ខ្លួនបាន[14]។ ប៉ុន្តែ គ្រប់បុគ្គលទាំងអស់មិនមែនសុទ្ធតែទទួលបានការធ្វើសកម្មភាពដោយខ្លួនឯងទាំងអស់ទេ ដោយសារតែច្បាប់បានកំណត់ពីការខ្វះសមត្ថភាពខាងឆន្ទៈគឺសំដៅដល់ជនដែលខ្វះសមត្ថភាពក្នុងការយល់ដឹង វិនិច្ឆ័យអំពីលទ្ធផលតាមច្បាប់នៃសកម្មភាពរបស់ខ្លួនដែលមានបញ្ហាបញ្ញាស្មារតី។

**កថាភាគទី៣ ៖ សមត្ថភាពក្នុងការធ្វើសកម្មភាព**

**សមត្ថភាពក្នុងការធ្វើសកម្មភាព** សំដៅទៅលើសមត្ថភាពដែលបុគ្គលម្នាក់អាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាពនិងដោយឯករាជ្យ។ ម្យ៉ាងទៀតបុគ្គលដែលមានសមត្ថភាពពេញលេញ អាចបង្ហាញពីឆន្ទៈប្រកបដោយសុពលភាព ដោយការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ដោយមិនចាំបាច់មានជំនួយពីបុគ្គលណាម្នាក់ឡើយ។

ជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះ នៅមុនពេលបង្ហាញឆន្ទៈរបស់ខ្លួន។ ប្រសិនបើជននោះមិនបានទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈទេ នោះសកម្មភាពដែលបានធ្វើនោះអាចលុបចោលបាន។ ជនដែលត្រូវកម្រិតសមត្ថភាពគឺ អនីតិជន ( អាយុក្រោម១៨ឆ្នាំ លើកលែង អនីតិជនដែលទទួលអត្តាធីនភាព ) ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។

[14] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១-៣ ឆ្នាំ២០១៧ ( ទំព័រ ១៥ )

# ជំពូកទី២
# កិច្ចសន្យាបញ្ញើមិនយកកម្រៃ

# ជំពូកទី២

# កិច្ចសន្យាបញ្ញើមិនយកកម្រៃ

## ផ្នែកទី១៖ សញ្ញាណនៃកិច្ចសន្យាបញ្ញើមិនយកកម្រៃ

### កថាភាគទី១៖ និយមន័យ

**កិច្ចសន្យា** គឺជាការព្រមព្រៀងរវាងបុគ្គលពីរឬច្រើនមានឆន្ទៈរួមគ្នាព្រមបង្កើត កែប្រែឬរំលត់កាតព្វកិច្ច។

**បញ្ញើ** សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ហើយ នៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុនោះមកអ្នកផ្ញើវិញ[15]។

**កិច្ចសន្យាបញ្ញើមិនយកកម្រៃ** ជាកិច្ចសន្យាដែលកើតពីបុគ្គលពីរឬច្រើននាក់ ដែលមានភាគីម្ខាងជាអ្នកទទួលបញ្ញើសន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលកំណត់ណាមួយក្រោយពីអំឡុងពេលនោះបានបញ្ចប់គឺ អ្នកទទួលបញ្ញើត្រូវសងវត្ថុនោះទៅឱ្យអ្នកផ្ញើវិញដោយគ្មានគិតកម្រៃ។

### កថាភាគទី២៖ លក្ខណៈនៃកិច្ចសន្យាបញ្ញើមិនយកកម្រៃ

កិច្ចសន្យាបញ្ញើមិនយកកម្រៃមានលក្ខណៈជាកិច្ចសន្យាមុធា។

**កិច្ចសន្យាមុធា** គឺជាកិច្ចសន្យាដែលភាគីម្ខាងជាអ្នកខាត និងភាគីម្ខាងទៀតជាអ្នកចំណេញ មានន័យថាភាគីម្ខាងបម្រើផលប្រយោជន៍ ដល់ភាគីម្ខាងទៀត ដោយគ្មានបានទទួលផលអ្វីពីភាគីដែលបានទទួលផលប្រយោជន៍នោះ។

**ឧទាហរណ៍៖** កិច្ចសន្យាបញ្ញើមិនយកកម្រៃ។

កិច្ចសន្យាបញ្ញើមិនយកកម្រៃ អ្នកទទួលបញ្ញើមិនទទួលបានផលប្រយោជន៍អ្វី ពីអ្នកផ្ញើឡើយ។ អ្នកទទួលបញ្ញើ គឺមានកាតព្វកិច្ចរក្សាទុកវត្ថុបញ្ញើដើម្បីជាផលប្រយោជន៍របស់អ្នកផ្ញើតែប៉ុណ្ណោះ។

ជាគោលការណ៍ទូទៅ បញ្ញើនឹងមិនបង្កើតអានុភាពឡើយ ប្រសិនបើគ្មានការផ្ទេរការកាន់កាប់ពីអ្នកផ្ញើនិងអ្នកទទួលបញ្ញើ បានទទួលយកវត្ថុនោះមកកាន់កាប់[16]។ ប្រសិនបើគ្មានការប្រគល់វត្ថុទេ កិច្ចសន្យានេះក៏មិនអាចកើតមានបានដែរ។ វាជាការចាំបាច់ប្រគល់វត្ថុទើបកិច្ចសន្យាបញ្ញើមិនយកកម្រៃអាចបង្កើតមានឡើង ប៉ុន្តែមានករណីលើកលែង ដោយកិច្ចសន្យាកើតឡើងត្រឹមតាមការព្រមព្រៀងគ្នាដោយមិនមានការប្រគល់វត្ថុ ក៏កិច្ចសន្យានោះ មានអានុភាពបានដែរ។ ប៉ុន្តែ តាមការជាក់ស្តែង បញ្ញើដោយការព្រមព្រៀងជា កិច្ចសន្យាជាមុនអំពី

[15] មាត្រា ៦៦៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[16] សូមមើលមាត្រា៦៧០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បញ្ញើនាពេលអនាគត ហេតុនេះហើយវាមិនសមរម្យទេ ក្នុងការផ្តល់ឱ្យមានអានុភាពចងខ្លាំងពេកនោះ។

ការផ្ទេរការកាន់កាប់អាចធ្វើឡើងដោយ ការប្រគល់ដោយជាក់ស្តែង ការផ្ទេរការកាន់កាប់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។

- **ការប្រគល់ដោយជាក់ស្តែង**

ការកាន់កាប់ត្រូវបានផ្ទេរ ដោយការប្រគល់វត្ថុកាន់កាប់។ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការប្រគល់ដោយជាក់ស្តែង[17]។

អ្នកផ្ញើប្រគល់វត្ថុបញ្ញើដោយផ្ទាល់ទៅឱ្យអ្នកទទួលបញ្ញើកាន់កាប់[18]។

**ឧទាហរណ៍៖** លោក "ក" បានយកកាបូប ទៅផ្ញើនឹងលោក "ខ" ដោយផ្ទាល់តាមការព្រមព្រៀង។

- **ការផ្ទេរការកាន់កាប់ដោយសង្ខេប**

បើអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយី នៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់។ ការកាន់កាប់បែបនេះ ហៅថាការប្រគល់ដោយសង្ខេប[19]។

ក្នុងករណីដែលអ្នកទទួលបញ្ញើ បានកាន់កាប់កម្មវត្ថុនៃបញ្ញើនោះហើយ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយការព្រមព្រៀងបង្កើតទំនាក់ទំនងបញ្ញើនោះ[20]។ កិច្ចសន្យាបញ្ញើ តម្រូវឱ្យមានការប្រគល់នូវកម្មវត្ថុដើម្បីបង្កើតអានុភាព ប៉ុន្តែ ប្រសិនបើអ្នកដែលត្រូវទទួលបញ្ញើបានរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុរួចហើយ វាមិនមានប្រយោជន៍អ្វីដែលត្រូវប្រគល់វត្ថុនោះទៅឱ្យអ្នកផ្ញើវិញ ដើម្បីឱ្យអ្នកផ្ញើធ្វើការប្រគល់វត្ថុនោះជាថ្មីម្តងទៀតទៅអ្នកទទួលបញ្ញើនោះទេ។ ដោយអ្នកទទួលបញ្ញើកំពុងកាន់កាប់វត្ថុបញ្ញើនោះស្រាប់។ ហេតុនេះភាគីគ្រាន់តែព្រមព្រៀងគឺ បង្កើតអានុភាព។

**ឧទាហរណ៍៖** A លក់វត្ថុមួយដែលខ្លួនកាន់កាប់ក្នុងនាមជាកម្មសិទ្ធិករឱ្យទៅ B ប៉ុន្តែតាមការជាក់ស្តែង មិនបានផ្ទេរការកាន់កាប់វត្ថុនោះទៅឱ្យ B ហើយបន្តរក្សាវត្ថុនោះក្នុងនាម ( A ) ជាអ្នកទទួលបញ្ញើ តាមការព្រមព្រៀង។ នេះគឺជាការបង្កើតកិច្ចសន្យាបញ្ញើដោយ "ការប្រគល់ដោយសង្ខេប"។

- **ការផ្ទេរការកាន់កាប់ដោយបញ្ជា**

អ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃអាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបានដោយការព្រម-

[17] មាត្រា ២២៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] សូមមើលមាត្រា ៦៧០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] មាត្រា ២២៩ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[20] មាត្រា ៦៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ព្រៀងជាមួយនឹងតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ។ ការផ្ទេរការកាន់កាប់បែបនេះហៅថា ការផ្ទេរការកាន់កាប់ដោយបញ្ជា[21]។

ចំពោះវត្ថុដែលកាន់កាប់ដោយតតិយជន កិច្ចសន្យាបញ្ញើត្រូវបានបង្កើត នៅពេលដែលបានផ្ទេរការកាន់កាប់ដោយការបញ្ជា[22]។ វត្ថុកាន់កាប់ដោយតតិយជន ត្រូវបានប្រគល់ទៅឱ្យអ្នកទទួលបញ្ញើ តាមបញ្ជារបស់អ្នកផ្ញើក៏កិច្ចសន្យាបញ្ញើនោះបង្កើតអានុភាពដែរ។

**ឧទាហរណ៍៖** នៅពេល A ជាអ្នកកាន់កាប់ឃ្លាំង ( អ្នកទទួលបញ្ញើ ) កំពុងរក្សាទុកវត្ថុរបស់អ្នកផ្ញើ B ប្រសិនបើ B ផ្ទេរកម្មសិទ្ធិលើវត្ថុនោះឱ្យទៅ C មានករណីខ្លះ C មានបំណងបន្តកិច្ចសន្យាស្តុកទំនិញជាមួយA ។ ក្នុងករណីនេះ កិច្ចសន្យាបញ្ញើរវាង C និង A ត្រូវបានបង្កើតឡើង នៅពេលដែល B បញ្ជាឱ្យ A ថាត្រូវកាន់កាប់វត្ថុនោះសម្រាប់ C ក្រោយពេលធ្វើការបញ្ជានោះ។

នៅក្នុងកិច្ចសន្យាបញ្ញើមិនយកកម្រៃ ជាគោលការណ៍ បញ្ញើ ធ្វើឡើងដោយមិនយកកម្រៃឡើយ ហេតុនេះមានតែអ្នកទទួលបញ្ញើប៉ុណ្ណោះដែលមានករណីយកិច្ចរក្សាវត្ថុ និងប្រគល់វិញនូវវត្ថុផ្ញើ រីឯអ្នកផ្ញើមិនមានករណីយកិច្ចអ្វីទាំងអស់[23]។

ក្នុងសង្គមជាក់ស្តែង វត្ថុមួយចំនួនត្រូវបានគេរក្សាទុកដោយមិនយកកម្រៃ **ឧទាហរណ៍៖** ដូចជាការថែ-រក្សាអីវ៉ាន់ឱ្យមានសុវត្ថិភាពនៅសារមន្ទីរ និងការថែរក្សាវត្ថុមានតម្លៃនៅ សណ្ឋាគារឱ្យមានសុវត្ថិភាពជាដើម។ លើកលែងតែអ្នកទទួលបញ្ញើនោះទទួលបញ្ញើក្នុងនាមអាជីវកម្មរបស់ខ្លួន ដូចជាអាជីវកម្មឃ្លាំងស្តុកទំនិញ។

## ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចរបស់អ្នកផ្ញើ

ដោយសារតែកិច្ចសន្យាបញ្ញើមិនយកកម្រៃនេះ ជាកិច្ចសន្យាឯកតោភាគី ដែលនាំឱ្យចងកាតព្វកិច្ចភាគីតែម្ខាង ដែលអ្នកផ្ញើគ្មានករណីយកិច្ចអ្វីទាំងអស់។ ប៉ុន្តែប្រសិនបើក្នុងករណីដែលកិច្ចសន្យានេះបានប្រែក្លាយទៅជាកិច្ចសន្យាអញ្ញមញ្ញៈវិញ ដែលនាំឱ្យអ្នកផ្ញើមានករណីយកិច្ចមួយចំនួន។

### កថាភាគទី១៖ សិទ្ធិរបស់អ្នកផ្ញើ

សិទ្ធិរបស់អ្នកផ្ញើមាន៖

#### ក. ការទាមទារវត្ថុបញ្ញើ

ទោះបីជាភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយអ្នកផ្ញើ អាចទាមទារឱ្យសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន[24]។ ដោយសារតែបញ្ញើនេះធ្វើឡើង ដើម្បីផលប្រយោជន៍របស់អ្នកផ្ញើ ហើយអ្នកទទួល

---

[21] មាត្រា ២២៩ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[22] មាត្រា ៦៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] សូមមើលមាត្រា ៦៦៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បញ្ញើមិនមានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្នុងការបន្តបញ្ញើទេ។ ហេតុនេះហើយ បើទោះជាកិច្ចសន្យានេះមានកំណត់អំឡុងពេលក៏ដោយ ក៏អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះ នៅពេលណាក៏បានដែរ។

**ខ. ការដកការព្រមព្រៀងចំពោះបញ្ញើនៅពេលអនាគត**

បើទោះជាមានការព្រមព្រៀង ថានឹងកើតកិច្ចសន្យានាពេលអនាគតក៏ដោយ ក៏អ្នកផ្ញើមានសិទ្ធិដកការព្រមព្រៀងនោះ ពេលណាក៏បានព្រោះវាជាកិច្ចសន្យាបញ្ញើមិនយកកម្រៃ[25]។

**ឧទាហរណ៍ ៖** ភាគីទាំងពីរព្រមព្រៀងគ្នាថា ភាគី "ក" បានផ្ញើកាបូប ( បញ្ញើមិនយកកម្រៃ ) ទុកនៅភាគី "ខ" ព្រោះមេឃភ្លៀង ប៉ុន្តែដល់ពេលភាគី "ក" ថាមិនបាច់ផ្ញើទេព្រោះគាត់ត្រូវការកាបូបនិងប្រើនៅថ្ងៃស្អែក ហេតុនេះហើយគាត់អាចដកការព្រមព្រៀងនេះបាន ព្រោះវាមិនបានផ្តល់នូវព្យសនកម្មអ្វីដល់ភាគី "ខ" ឡើយ។

**គ. ការទាមទារសំណង**

អ្នកផ្ញើអាចទាមទារការខូចខាតបាន ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើឱ្យបាត់បង់ ឬបាក់បែកវត្ថុបញ្ញើដោយកំហុសរបស់អ្នកទទួលបញ្ញើតែប៉ុណ្ណោះ[26]។ ហើយការទាមទារសំណងត្រូវមានតម្លៃសមរម្យ ឬជាតម្លៃរបស់វត្ថុបញ្ញើតែប៉ុណ្ណោះ មិនអាចទាមទារលើសបានទេព្រោះនេះជាកិច្ចសន្យាបញ្ញើមិនយកកម្រៃ។

បើបញ្ញើត្រូវបានធ្វើឡើងដោយការទាមទាររបស់អ្នកទទួលបញ្ញើ រួមទាំងទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការ្យផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើបានទទួលវត្ថុបញ្ញើពីភ្ញៀវ ក្នុងករណីមានការបាត់បង់ ឬបែកបាក់វត្ថុបញ្ញើនោះអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត[27] ទោះបីជាគ្មានកំហុសក៏ដោយ។

**ឧទាហរណ៍៖** បើវត្ថុនោះមានតម្លៃ១០០០០០៛ គឺត្រូវសងតែ១០០០០០៛ នឹងតែប៉ុណ្ណោះ។

**កថាភាគទី២ ៖ករណីយកិច្ចរបស់អ្នកផ្ញើ**

នៅក្នុងករណីដែលកិច្ចសន្យាបញ្ញើមិនយកកម្រៃប្រែក្លាយជាកិច្ចសន្យាអញ្ញមញ្ញៈ ហេតុនេះបានជាអ្នកផ្ញើមានករណីយកិច្ចដូចជា ៖

**ក. ទទួលបន្ទុកសោហ៊ុយនៃការសងបញ្ញើ**

ក្នុងករណីបញ្ញើដោយមិនយកកម្រៃ វាមិនសមរម្យទេដែលអ្នកទទួលបញ្ញើត្រូវទទួលបន្ទុកលើសោហ៊ុយសម្រាប់ការសងនោះ។ នៅក្នុងបញ្ញើដោយមិនយកកម្រៃ សោហ៊ុយសម្រាប់ការសងគឺជា បន្ទុករបស់អ្នកផ្ញើក្នុងករណីអ្នកផ្ញើ មានកំហុសដោយអ្នកផ្ញើផ្លាស់ប្តូរ ទីកន្លែងទទួលបញ្ញើ ប៉ុន្តែបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរទីកន្លែង

---

[25] សូមមើលមាត្រា ៦៧១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[26] សូមមើលមាត្រា ៦៧៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] សូមមើលមាត្រា ៦៧៤ កថាខណ្ឌទី២និង៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្ញើសោហ៊ុយនៃការសងដែលកើតឡើងដោយសារ ការផ្លាស់ប្តូរទីកន្លែងនោះគឺជាបន្ទុករបស់អ្នកទទួលបញ្ញើ[28]។

### ខ. សោហ៊ុយសម្រាប់ការរក្សាទុក

អ្នកផ្ញើ ចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ[29]។ សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើ និង កម្រៃសម្រាប់ការរក្សាទុកវត្ថុបញ្ញើ គឺមិនដូចគ្នាទេ។ សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុ គឺជាសោហ៊ុយចំណាយជាក់ស្តែងសម្រាប់ការរក្សាទុកវត្ថុ រីឯកម្រៃសម្រាប់ការរក្សាទុកវត្ថុ គឺជាថ្លៃសេវា ឬ កម្លាំងពលកម្មរបស់អ្នកទទួលបញ្ញើក្នុងការរក្សាទុកវត្ថុរបស់អ្នកទទួលបញ្ញើ។ វត្ថុមួយចំនួនមិនចាំបាច់មានសោហ៊ុយសម្រាប់ការរក្សាទុកទេ ប៉ុន្តែវត្ថុមួយចំនួនទៀតចាំបាច់ត្រូវមានសោហ៊ុយសម្រាប់ការរក្សាទុក ដើម្បីរក្សាស្ថានភាពដើម ឬ គុណភាពរបស់វាឱ្យនៅដដែល ដូចជា សាច់គោដែលចាំបាច់ត្រូវរក្សាទុកក្នុងទូក្លាសេ ជាដើម។ ដូច្នោះប្រសិនបើអ្នកទទួលបញ្ញើបានចំណាយសោហ៊ុយចាំបាច់សម្រាប់ ការរក្សាទុកវត្ថុបញ្ញើនោះអ្នកទទួលបញ្ញើអាចទាមទារឱ្យសងសោហ៊ុយវិញពីអ្នកផ្ញើបាន **ឧទាហរណ៍**ដូចជា ថ្លៃអគ្គិសនី ជាអាទិ៍។

## ផ្នែកទី៣៖ សិទ្ធិ និងករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

ដោយសារតែកិច្ចសន្យាបញ្ញើមិនយកកម្រៃនេះជាកិច្ចសន្យាឯកតោភាគី មានន័យថាអ្នកទទួលបញ្ញើមិនមានសិទ្ធិអ្វីទាំងអស់មានតែករណីយកិច្ចទេ។

ប៉ុន្តែប្រសិនបើ ក្នុងករណីដែលកិច្ចសន្យានេះបានប្រែក្លាយទៅជា កិច្ចសន្យាអញ្ញមញ្ញៈវិញគឺមានន័យថាអ្នកទទួលបញ្ញើគឺមានសិទ្ធិឃាត់ទុក។

### កថាភាគទី១៖ សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើ អាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយនិងសំណងនៃការខូចខាត[30]។ សិទ្ធិឃាត់ទុកនេះដើម្បីអនុវត្តន៍សិទ្ធិ ទាមទារសោហ៊ុយសម្រាប់ការរក្សាទុក និង សំណងខូចខាតដែលបណ្តាលមកពីវត្ថុបញ្ញើ។

**ឧទាហរណ៍៖** លោក "គ" គាត់បានទិញសាច់គោ១០គីឡូក្រាម ក្នុងបំណងជប់លៀងពេលល្ងាចថៃដន្យ គាត់មានការជាបន្ទាន់ត្រូវចុះមកខេត្ត ហេតុនេះហើយបានជាគាត់បានយកទៅផ្ញើនឹងលោក "ឃ" ដោយបញ្ញើមិនយកប្រាក់ព្រោះលោក "គ" គាត់ប្រាប់ថាទៅតែមួយថ្ងៃ ប៉ុន្តែគាត់ទៅបាត់មួយសប្តាហ៍ទើបមកវិញ ដែលជាហេតុធ្វើឱ្យលោក "ឃ" រងព្យសនកម្មដោយសារតែសាច់គោនឹងត្រូវក្លាសេហើយលោក "ឃ" មិនអាចបិទផ្ទះទៅណាបាន ព្រោះបើគាត់បិទផ្ទះគឺគាត់ត្រូវដកឌុយទូរទឹកកកដើម្បីចៀសវាងគ្រោះថ្នាក់ជាយថាហេតុ ហេតុនេះហើយនៅ

[28] មាត្រា ៦៨៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[29] មាត្រា៦៨៦ ចំណុច១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

30 សូមមើលមាត្រា ៦៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ពេលដែលលោក "ឃ" ត្រលប់មកវិញគឺត្រូវចេញថ្លៃខាតបង់របស់លោក "គ" ប្រសិនបើលោក "គ" មិនព្រមសងទេ នោះលោក "ឃ" មានសិទ្ធិឃាត់ទុករហូតដល់លោក "គ" ព្រមសងទើបប្រគល់សាច់គោនោះទៅឱ្យលោក "គ" វិញ។

**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ**

ករណីយកិច្ចរបស់អ្នកទទួលបញ្ញើមាន៖

**ក. ករណីយកិច្ចថែរក្សាវត្ថុបញ្ញើ**

អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើមិនអាចប្រើវត្ថុបញ្ញើបានឡើយ[31]។ ប្រសិនជាមានការអនុញ្ញាតពីអ្នកផ្ញើ អ្នកទទួលបញ្ញើអាចប្រើវត្ថុនោះបាន ដូចជានៅក្នុងបញ្ញើបរិភោគ គឺអ្នកទទួលបញ្ញើអាចបរិភោគវត្ថុបញ្ញើបាន បើមានការព្រមព្រៀងគ្នារវាងអ្នកទទួលបញ្ញើ និងអ្នកផ្ញើ បន្ទាប់មកអ្នកទទួលបញ្ញើសងវត្ថុបញ្ញើដែលមានប្រភេទនិងចំនួនដូចគ្នា មានចែងក្នុងមាត្រា៦៩០នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**ខ. ការរក្សាទុកដោយខ្លួនឯង**

ជាធម្មតាមុនសម្រេចចិត្តផ្ញើ អ្នកផ្ញើបានពិចារណាអំពីជំនាញ និង លក្ខខ័ណ្ឌដទៃផ្សេងទៀតរបស់អ្នកទទួលបញ្ញើ នៅពេលសម្រេចផ្ញើវត្ថុនោះ ហេតុដូច្នេះ វាមិនសមរម្យទេដែលអ្នកទទួលបញ្ញើនោះផ្ញើបន្តនូវវត្ថុបញ្ញើនោះទៅតតិយជនដោយសេរី។ ដូចនេះ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ។ ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឱ្យតតិយជនរក្សាវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និងត្រួតពិនិត្យអ្នកទទួលបញ្ញើដែលត្រូវបានឱ្យរក្សាទុកបន្ត[32]។

**គ. ករណីយកិច្ចជូនដំណឹង**

ការជូនដំណឹងជាកាតព្វកិច្ចរបស់អ្នកទទួលបញ្ញើ ដោយសារតែមានបុគ្គលណា ឬ បុគ្គលមួយក្រុមណាបានអះអាងថាវត្ថុបញ្ញើនោះជាកម្មសិទ្ធិរបស់ខ្លួន ឬមានលិខិតបញ្ជាក់ច្បាស់លាស់ ហេតុនេះហើយបានជាអ្នកទទួលបញ្ញើមាន ករណីយកិច្ចជូនដំណឹងទៅអ្នកផ្ញើភ្លាមៗតាមមធ្យោបាយផ្សេងៗដែលអាចធ្វើទៅបាន ដើម្បីអាចតតាំងជាមួយបុគ្គល ឬ ក្រុមបុគ្គលណាមួយដែលអះអាងថាជាម្ចាស់កម្មសិទ្ធិនៃវត្ថុបញ្ញើនោះបាន។ ដោយហេតុនេះហើយ ប្រសិនបើតតិយជនដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើ ត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះទៅឱ្យអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ[33]។

[31] មាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[32] មាត្រា ៦៧៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា ៦៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ឃ. ករណីយកិច្ចសងវត្ថុដែលផ្ញើ

អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ[34]។ ក្នុងករណីបញ្ញើបរិភោគវិញ អ្នកទទួលបញ្ញើអាចបរិភោគវត្ថុដែលត្រូវបានផ្ញើដោយអ្នកផ្ញើនោះ ហើយនៅពេលកំណត់សង អ្នកទទួលបញ្ញើអាចសងវត្ថុដែលមានប្រភេទដូចគ្នាមកសងវិញ[35]។

**ឧទាហរណ៍៖** ផ្ញើសៀវភៅសងវិញសៀវភៅ ផ្ញើប៊ិចសងវិញប៊ិច គឺមិនអាចសងអ្វីខុសពីនេះបានទេ។

ប្រសិនបើ ភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន។

ប្រសិនបើមានការកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើនៅមុនពេលកំណត់បានឡើយ[36]។

ប្រសិនបើមិនបានកំណត់ក្នុងកិច្ចសន្យា ការសងវត្ថុបញ្ញើ ចាំបាច់ធ្វើនៅកន្លែងដែលរក្សាវត្ថុបញ្ញើនោះ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងរក្សាទុកវត្ថុនោះ ដោយមូលហេតុត្រឹមត្រូវការសងអាចធ្វើនៅកន្លែងរក្សាទុកជាក់ស្តែងនាពេលសងបាន[37]។

### ង. ការសងការខូចខាត

អ្នកទទួលបញ្ញើត្រូវតែសងការខូចខាតចំពោះការខូចខាតដែលខ្លួនបានធ្វើឱ្យមានកំហុស បើទោះជាកិច្ច-សន្យានេះជា កិច្ចសន្យាមិនយកកម្រៃក៏ដោយ ព្រោះការខូចខាតនេះកើតឡើងដោយសារតែ ការធ្វេសប្រហែសរបស់យើង។ ក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើ ត្រូវសងសំណងនៃការខូចខាតនោះ[38]។ បើទោះជាត្រូវសងក៏សងតាមតម្លៃសមរម្យដែរ ម្យ៉ាងទៀតការសងនេះមើលតាមលទ្ធភាពរបស់អ្នកទទួលបញ្ញើ។ ក្នុងករណីដែលបញ្ញើមិនត្រូវបានធ្វើឡើងដោយឆន្ទៈសេរីរបស់អ្នកផ្ញើទេ ប៉ុន្តែ ធ្វើទៅតាមការទាមទាររបស់អ្នកទទួលបញ្ញើ ក្នុងស្ថានភាពជាក់លាក់ណាមួយ បើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យ បាត់បង់ ឬ បែកបាក់បានឡើយ[39]។

**ឧទាហរណ៍៖** នៅពេលដែលនរណាម្នាក់ ចូលទៅក្នុងបណ្ណាល័យ ឬសារមន្ទីរគាត់ត្រូវបានទាមទារឱ្យ

---

[34] មាត្រា ៦៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[35] សេចក្តីកំណត់នៃក្រមរដ្ឋប្បវេណី គន្លឹទី៥ ទំព័រទី១៣១-១៣២

[36] មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[37] មាត្រា ៦៨៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[38] មាត្រា ៦៧៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[39] មាត្រា ៦៧៤ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ផ្ញើអីវ៉ាន់របស់គាត់នៅបណ្ណាល័យ ឬ សារមន្ទីរនោះ។

នៅទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិល្បៈការផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិល្បៈការទាំងឡាយនោះ បានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យ បាត់បង់ ឬ បែកបាក់បានឡើយ[40]។ ក្នុងករណីនេះអ្នកទទួលបញ្ញើត្រូវសងការខូចខាត។

**កថាភាគទី៣៖ ការរួចផុតពីការទទួលខុសត្រូវអ្នកទទួលបញ្ញើ**

បើទោះជាកិច្ចសន្យានេះមិនយកកម្រៃ ក៏អ្នកទទួលបញ្ញើមានការទទួលខុសត្រូវអំពីការធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យបែកបាក់វត្ថុបញ្ញើដែលព្រោះវាជាកំហុសរបស់អ្នកទទួលបញ្ញើ ប៉ុន្តែមានករណីលើកលែង ប្រសិនបើការបាត់បង់ ឬ បែកបាក់នោះមិនមែនជាកំហុសរបស់ខ្លួនដែលកើតឡើង ក្នុងករណីប្រធានសក្តិ ដោយមានការបញ្ជាក់នោះអ្នកទទួលបញ្ញើអាចរួចផុតពីការទទួលខុសត្រូវបាន[41]។

**ឧទាហរណ៍ទី១៖** A យកម៉ូតូទៅផ្ញើនៅផ្ទះរបស់ B ដោយបញ្ញើមិនយកកម្រៃ។ បន្ទាប់មកដោយអាកាសធាតុមានការប្រែប្រួលមានខ្យល់កន្ត្រាក់ ដែលបណ្តាលឱ្យផ្ទះរបស់ B រលំសង្កត់ម៉ូតូរបស់ A មានការខូចខាតយ៉ាងដំណំ។ ក្នុងករណីនេះ B អាចលើកឡើងពីករណីប្រធានសក្តិ ដើម្បីអាចរួចផុតពីការទទួលខុសត្រូវបាន។

បើផ្ញើឥតឈ្នួល ហើយបញ្ញើនោះត្រូវអន្តរាយដោយចោរកម្ម អ្នកទទួលបញ្ញើមិនត្រូវសងទេ ប្រសិនបើអ្នកទទួលបញ្ញើមានភស្តុតាងបញ្ជាក់ថា ខ្លួនមានការប្រុងប្រយ័ត្នដែរក្នុងការរក្សាបញ្ញើនោះ[42]។

**ឧទាហរណ៍ទី២៖** A យកម៉ូតូទៅផ្ញើនឹង B ដោយបញ្ញើមិនយកកម្រៃ។ បន្ទាប់មក B បានទទួលបញ្ញើដោយរក្សាទុកយ៉ាងប្រុងប្រយត្ន័ ប៉ុន្តែ នៅតែចោរអាចលួចយកបានមិនត្រឹមតែ លួចយកម៉ូតូរបស់ A ទេ សូម្បីតែម៉ូតូរបស់ B ក៏ចោរលួចដែរ។ ក្នុងករណីនេះ B អាចរួចផុតពីការទទួលខុសត្រូវបាន ព្រោះគាត់ ( B ) បានរក្សាទុកយ៉ាងប្រុងប្រយត្ន័ហើយ ប៉ុន្តែចោរនៅតែអាចគាស់យកបាន។ ប៉ុន្តែបើក្នុងករណីដែល B រក្សាទុកម៉ូតូរបស់ A ដោយការធ្វេសប្រហែសវិញ គឺ B មិនអាចរួចផុតពីការទទួលខុសត្រូវបានទេ។

នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និង វត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀតប្រសិនបើអ្នកផ្ញើ មិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន[43]។

[40] មាត្រា ៦៧៤ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[41] សូមមើលមាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[42] មាត្រា ៩៣ នៃក្រឹត្យ ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

[43] មាត្រា ៦៧៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍ទី៣៖** លោក "ក" បានព្រមព្រៀងផ្ញើកាបូបជាមួយកញ្ញា "ខ" ក្នុងករណីនៅក្នុងកាបូបរបស់លោក "ក" មានវត្ថុមានតម្លៃលោក "ក" ត្រូវរាយការណ៍ប្រាប់កញ្ញា "ខ" ឱ្យបានដឹង។ ក្នុងករណីមិនបានរាយការណ៍ ហើយកញ្ញា "ខ" បានធ្វើឱ្យមានការខូចខាត នោះតុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងការខូចខាតបាន។

នៅក្នុងបញ្ញើមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃ ការខូចខាតរបស់អ្នកផ្ញើដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាងនិងកាលៈទេសៈផ្សេងៗទៀត[44]។

[44] មាត្រា ៦៧៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣

# កិច្ចសន្យាបញ្ញើយកកម្រៃ

# ជំពូកទី៣
# កិច្ចសន្យាបញ្ញើយកកម្រៃ

## ផ្នែកទី១៖ សញ្ញាណនៃកិច្ចសន្យាបញ្ញើយកកម្រៃ

### កថាភាគទី១៖ និយមន័យ

**កិច្ចសន្យាបញ្ញើយកកម្រៃ** ជាកិច្ចសន្យាដែលកើតពីបុគ្គលពីរ ឬ ច្រើននាក់ដែលមានភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើពី ភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលកំណត់ណាមួយ ក្រោយពីអំឡុងពេលនោះបានបញ្ចប់គឺអ្នកទទួលបញ្ញើត្រូវសងវត្ថុនោះទៅឱ្យអ្នកផ្ញើវិញដោយយកកម្រៃ។

បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬ ប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើ អាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន[45]។ បញ្ញើដែលអ្នកទទួលបញ្ញើទទួលនូវការផ្ញើក្នុងនាមជា "អាជីវកម្ម" របស់ខ្លួន គឺជាបញ្ញើដែលអ្នកទទួលបញ្ញើនោះទទួលម្តងហើយម្តងទៀតពីបុគ្គលផ្សេងៗ ហើយដែលអ្នកទទួលបញ្ញើនោះទទួលបាននូវផលចំណេញ។ អាជីវកម្មឃ្លាំងស្តុកទំនិញជាបញ្ញើសម្រាប់អាជីវកម្មប៉ុន្តែការថែរក្សាវត្ថុមានតម្លៃនៅសណ្ឋាគារឱ្យមានសុវត្ថិភាព មិនមែនជាបញ្ញើសម្រាប់អាជីវកម្មទេ ពីព្រោះសណ្ឋាគារមិនបានទទួល ផលប្រយោជន៍អ្វីពីបញ្ញើនោះទេ។

ផ្អែកតាមនិយមន័យខាងលើ យើងអាចកំណត់បានដូចខាងក្រោម៖

បញ្ញើ គឺជាកិច្ចសន្យាផ្តល់សេវា ស្រដៀងនិងកិច្ចសន្យាការងារ អាណត្តិ និង កិច្ចសន្យាម៉ៅការ ដែរ។ ប៉ុន្តែសេវាដែលអ្នកទទួលបញ្ញើត្រូវផ្តល់ គឺគ្រាន់តែជា "ការរក្សាទុកវត្ថុ" ប៉ុណ្ណោះ។ ប្រសិនបើមានបន្ថែមសេវាផ្សេងទៀត ករណីខ្លះកិច្ចសន្យានោះអាចនឹងក្លាយជាកិច្ចសន្យាម៉ៅការ។ **ឧទាហរណ៍** ដូចជា កិច្ចសន្យាមួយដែលតាមរយៈនោះ អ្នកដំណើរប្រគល់អីវ៉ាន់ទៅ ក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវរថភ្លើងនៅឯស្ថានីយ៍ដែលអ្នកដំណើរត្រូវជិះ ហើយអ្នកដំណើរត្រូវទទួលអីវ៉ាន់នោះនៅ ស្ថានីយ៍ដែលខ្លួនទៅដល់ សេវាបែបនេះមិនមែនគ្រាន់តែជាការរក្សាទុកអីវ៉ាន់ប៉ុណ្ណោះទេ ដោយសារតែសេវាដឹកជញ្ជូនអីវ៉ាន់ឱ្យដល់គោលដៅត្រូវបានបន្ថែម។ សេវារក្សាទុកវត្ថុ គឺជាលក្ខខណ្ឌចាំបាច់នៃកិច្ចសន្យាបញ្ញើ។ ប្រសិនបើមិនមានការផ្តល់សេវារក្សាទុកវត្ថុទេ បញ្ញើក៏មិនត្រូវបានបង្កើតឡើងដែរ។ **ឧទាហរណ៍ ៖** ដូចជាករណីដែលម្ចាស់រថយន្តយករថយន្តទៅចតនៅចំណតផ្សារទំនើប ដែលម្ចាស់ចំណតមិនទទួលយកកូនសោរថយន្តមករក្សាទុកទេ គឺមិនមែនជាកិច្ចសន្យាបញ្ញើទេ តែជាកិច្ចសន្យាជួលចំណត

[45] មាត្រា ៦៦៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

( ភតិសន្យា ) ក្នុងករណីបង់ថ្លៃ និង ជាកិច្ចសន្យាខ្ចីប្រើ ក្នុងករណីមិនបង់ថ្លៃ។

**កថាភាគទី២៖ លក្ខណៈនៃកិច្ចសន្យាបញ្ញើយកកម្រៃ**

កិច្ចសន្យាបញ្ញើយកកម្រៃមានលក្ខណៈជាកិច្ចសន្យាមូលា។

**កិច្ចសន្យាមូលា** ជាកិច្ចសន្យាដែលយកតម្លៃជាថ្នូរ ដូចក្នុងកិច្ចសន្យាបញ្ញើយកកម្រៃដែលយកប្រាក់ជាថ្នូរ ហើយមានផលប្រយោជន៍រៀងៗខ្លួន។

កាលពីដើមឡើយ បញ្ញើ ជាញឹកញាប់ត្រូវបានបង្កើត ក្នុងគោលបំណងគ្រាន់តែជួយយកអាសារគ្នាប៉ុណ្ណោះ ដោយអ្នកទទួលបញ្ញើមិនបានយកកម្រៃពីការរក្សាទុកវត្ថុបញ្ញើឡើយ។ ប៉ុន្តែក្រោយមកបញ្ញើកាន់តែមានភាពចាំបាច់ ហើយតម្រូវការនៃបញ្ញើកាន់តែមានច្រើនឡើងៗបុគ្គលមួយចំនួនបានយកសកម្មភាពទទួលបញ្ញើធ្វើជាសកម្មវត្ថុនៃអាជីវកម្មរបស់ខ្លួន ដោយបានបង្កើតជាទីកន្លែងមានសុវត្ថិភាពសម្រាប់រក្សាទុកវត្ថុបញ្ញើ។ ដូច្នេះហើយ ចំពោះបញ្ញើដែលអ្នកទទួលបញ្ញើបានធ្វើជាមួយអ្នកផ្ញើ ក្នុងនាមជាអាជីវកម្មរបស់ខ្លួន ទោះបីជាមិនមានការសន្យាពិសេសអំពីការយកកម្រៃក៏ដោយ បញ្ញើនោះត្រូវបានចាត់ទុកជាបញ្ញើដោយយកកម្រៃ ហើយអ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន[46]។

ជាគោលការណ៍ទូទៅ បញ្ញើនឹងមិនបង្កើតអានុភាពឡើយ ប្រសិនបើគ្មានការផ្ទេរការកាន់កាប់ពីអ្នកផ្ញើ និងអ្នកទទួលបញ្ញើ បានទទួលយកវត្ថុបញ្ញើនោះមកកាន់កាប់[47]។ ដោយឡែកនៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ ការព្រមព្រៀងដែលបានបង្កើតឡើងត្រឹមការព្រមព្រៀងគ្នា ដោយមិនមានការប្រគល់វត្ថុក៏មានអានុភាពដែរ[48]។

**ឧទាហរណ៍៖** ប្រសិនបើ A ចង់ផ្ញើទំនិញទៅ B ដែលជាអ្នកកាន់កាប់ឃ្លាំងចាប់ពីថ្ងៃទី ១ ខែក្រោយ ហើយអ្នកកាន់កាប់ឃ្លាំងបានយល់ព្រម អ្នកកាន់កាប់ឃ្លាំងត្រូវរៀបចំកន្លែងសម្រាប់ដាក់ទំនិញផ្ញើ នៅថ្ងៃដែលបានសន្យា ដែលការណ៍នេះ តម្រូវឱ្យមានការរៀបចំ និងការគ្រប់គ្រងឃ្លាំង ( **ឧទាហរណ៍** ការគ្រប់គ្រងផែនការប្រើប្រាស់ឃ្លាំងដោយកុំព្យូទ័រ )។ ចំពោះអ្នកផ្ញើវិញ A នឹងធ្វើសកម្មភាពដោយផ្អែកលើការសន្និដ្ឋានថា អ្នកកាន់កាប់ឃ្លាំង នឹងធ្វើការថែរក្សាទុកទំនិញចាប់តាំងពីថ្ងៃ ដូចដែលបានព្រៀងទុកតាមការសន្យា ដោយគ្មានការខកខាន ពីព្រោះកិច្ចសន្យាស្តុកទំនិញជាកិច្ចសន្យាដោយយកកម្រៃ។ ហេតុដូច្នេះ វាជាភាពសមរម្យក្នុងការលើកកម្ពស់អានុភាពនៃកិច្ចសន្យាបញ្ញើដោយយកកម្រៃ។ អានុភាពនៃករណីយកិច្ចរក្សាទុក នូវវត្ថុរបស់អ្នកទទួលបញ្ញើ គឺខ្លាំង។ ប្រសិនបើអ្នកកាន់កាប់ឃ្លាំងបដិសេធមិនទទួលការប្រគល់វត្ថុបញ្ញើដោយគ្មានហេតុផល អ្នកកាន់កាប់ឃ្លាំងត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតចំពោះអ្នកផ្ញើ។ ចំណែកឯករណីយកិច្ចផ្ញើកម្មវត្ថុនៃបញ្ញើ របស់

[46] មាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[47] សូមមើលមាត្រា ៦៧០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[48] សូមមើលមាត្រា ៦៧១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អ្នកផ្ញើ មិនចាំបាច់ទទួលស្គាល់ឡើយ។ ទោះបីជាត្រូវគិតពិចារណាទៅដល់ផលប្រយោជន៍របស់អ្នកកាន់កាប់ឃ្លាំងក៏ដោយ ក៏វាមិនសមហេតុផលដែរក្នុងការចែងថា ប្រសិនបើ A ដែលជាអ្នកផ្ញើខកខានមិនបានដាក់កម្មវត្ថុនៃបញ្ញើ B ដែលជាអ្នកកាន់កាប់ឃ្លាំងអាចទាមទារឱ្យអ្នកផ្ញើដាក់កម្មវត្ថុនៃបញ្ញើបាន។

បញ្ញើយកកម្រៃ គឺជាកិច្ចសន្យាបង្កើតឱ្យភាគីទាំងសងខាងមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក។ ករណីនេះអ្នកផ្ញើមានកាតព្វកិច្ចបង់កម្រៃតបចំពោះកាតព្វកិច្ចរក្សាទុករបស់អ្នកទទួលបញ្ញើ។

**ផ្នែកទី២៖ សិទ្ធិនិងករណីយកិច្ចរបស់អ្នកផ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ អ្នកផ្ញើមានសិទ្ធិ និង ករណីយកិច្ចដូចខាងក្រោម ៖

**កថាភាគទី១៖ សិទ្ធិរបស់អ្នកផ្ញើ**

សិទ្ធិរបស់អ្នកផ្ញើមាន៖

**ក. សិទ្ធិទាមទារវត្ថុបញ្ញើ**

សិទ្ធិទាមទារវត្ថុបញ្ញើ ទាំងនៅក្នុងបញ្ញើយកកម្រៃ និងបញ្ញើមិនយកកម្រៃគឺអ្នកផ្ញើមានសិទ្ធិនេះដូចគ្នា។

ទោះបីជាភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន[49]។ ដោយសារបញ្ញើត្រូវបានធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកផ្ញើ អ្នកទទួលបញ្ញើមិនមានផលប្រយោជន៍ផ្ទាល់ខ្លួនអ្វីក្នុងការបន្តបញ្ញើទេ។ ហេតុដូចនេះទោះបីកិច្ចសន្យាបញ្ញើមានកំណត់អំឡុងពេលក៏ដោយក៏អ្នកផ្ញើអាចទាមទារឱ្យសងវិញនៅពេលណាក៏បាន។

**ខ. សិទ្ធិទាមទារសំណងនៃការខូចខាត**

ក្នុងករណីដែលបានសន្យាបង្កើតកិច្ចសន្យាបញ្ញើដោយបង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីដែលជាអ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតនោះ ទៅឱ្យភាគីម្ខាងទៀត ប្រសិនបើការបដិសេធនោះគ្មានមូលហេតុត្រឹមត្រូវ[50]។

នៅក្នុងករណីដែលបានធ្វើអោយបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើត្រូវសងសំណងនៃការខូចខាតនោះ[51]។

**ឧទាហរណ៍ ៖** A បានសន្យាជាមួយ B ឱ្យ B យកឡានទៅផ្ញើនៅផ្ទះរបស់ A ដោយយកកម្រៃ។ ប៉ុន្តែនៅពេលដែល B បានយកឡានទៅដល់ផ្ទះរបស់ A ស្រាប់តែ A មិនព្រមទទួលបញ្ញើដោយគ្មានមូលហេតុ។ ក្នុង

[49] មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[50] មាត្រា ៦៧១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[51] មាត្រា ៦៧៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ករណីនេះបញ្ជាក់ថា B អាចទាមទារសំណងនៃការខូចខាត ( ពេលវេលា ) ពី A បាន។ ប៉ុន្តែ ប្រសិនបើ Aគាត់មានមូលហេតុត្រឹមត្រូវវិញ ( ផ្ទះរបស់គាត់ចង្អៀតមិនអាចដាក់បាន ) គឺ A អាចរួចផុតពីការទទួលខុសត្រូវបាន។

**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកផ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃអ្នកផ្ញើមានករណីយកិច្ចដូចជា ៖

**ក. រាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើ**

នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍ដែលអាចជួញដូរបាន និងវត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀងអ្នកផ្ញើត្រូវរាយការណ៍អំពីប្រភេទ និងតម្លៃនៃវត្ថុបញ្ញើនោះទៅឱ្យអ្នកទទួលបញ្ញើបានដឹង។ ប្រសិនបើវត្ថុបញ្ញើជាវត្ថុមានតម្លៃអ្នកទទួលបញ្ញើ នឹងធ្វើការរក្សាទុកវត្ថុបញ្ញើដោយប្រុងប្រយ័ត្នពិសេស ដើម្បីកុំឱ្យមានការខូចខាត។ ផ្ទុយទៅវិញប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុបញ្ញើនោះជាវត្ថុដែលមានតម្លៃទេ អ្នកទទួលបញ្ញើនឹងធ្វើការប្រុងប្រយ័ត្នធម្មតាតែប៉ុណ្ណោះ។ ប៉ុន្តែវាជារឿងអកុសល ចំពោះអ្នកទទួលបញ្ញើហើយនៅពេលដែលខ្លួនទទួលនូវការទាមទារសំណងការខូចខាតដែលមានទំហំធំនៅក្រោយពេលដែលការខូចខាតបានកើតឡើងហើយនោះ។ លើសពីនេះទៅទៀត ដោយសារតែការរក្សាទុកនូវវត្ថុដែលមានតម្លៃ ទាមទារឱ្យមានការចំណាយយ៉ាងច្រើនសន្ធឹកសន្ធាប់ដែរនោះ អ្នកទទួលបញ្ញើទាមទារកម្រៃសម្រាប់ ការរក្សាទុកវត្ថុបញ្ញើនោះលើសពីធម្មតា។ ប៉ុន្តែប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថា វត្ថុនោះមានតម្លៃខ្ពស់ អ្នកទទួលបញ្ញើមិនអាចធ្វើដូច្នោះបានឡើយ។ ហេតុដូច្នោះហើយទើប មាត្រា៦៧៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកម្រិតករណីយកិច្ចដល់អ្នកផ្ញើឱ្យរាយ-ការណ៍ប្រាប់អ្នកទទួលបញ្ញើថាវត្ថុបញ្ញើនោះមានតម្លៃ។

**ខ. បង់កម្រៃសេវាវត្ថុបញ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើដោយយកកម្រៃ អ្នកផ្ញើមានករណីយកិច្ចបង់កម្រៃទៅឱ្យអ្នកទទួលបញ្ញើ ទៅតាមចំនួន ពេលវេលា និងទីកន្លែងដែលបានកំណត់។ ប្រសិនបើមិនបានកំណត់ចំនួននៃកម្រៃដែលត្រូវបង់ទេ អ្នកទទួលបញ្ញើអាចទាមទារនូវចំនួនសមរម្យបាន[52]។ ប្រសិនបើមិនបានកំណត់ពេលដែលត្រូវបង់កម្រៃទេ អ្នកផ្ញើត្រូវបង់កម្រៃនៅពេលណាដែលអ្នកទទួលបញ្ញើទាមទារឱ្យបង់[53]។ ប្រសិនបើ មិនបានកំណត់ទីកន្លែងដែលត្រូវបង់កម្រៃទេ អ្នកផ្ញើត្រូវបង់នៅលំនៅឋានរបស់អ្នកទទួលបញ្ញើ[54]។

**ផ្នែកទី៣៖ សិទ្ធិ និង ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ**

ដោយសារតែកិច្ចសន្យាបញ្ញើយកកម្រៃជា កិច្ចសន្យាអញ្ញមញ្ញៈដែលនាំឱ្យអ្នកទទួលបញ្ញើមានសិទ្ធិ និង

[52] សូមមើលមាត្រា៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[53] សូមមើលមាត្រា ៤៤៣ កថាខណ្ឌទី១ និងមាត្រា ៣៩១ ចំណុចគ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[54] សូមមើលមាត្រា ៤៤៥ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ករណីយកិច្ចដូចជា៖

**កថាភាគទី១៖ សិទ្ធិរបស់អ្នកទទួលបញ្ញើ**

សិទ្ធិរបស់អ្នកទទួលបញ្ញើមាន៖

**ក. សិទ្ធិទាមទារកម្រៃនៃសេវាបញ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ អ្នកទទួលបញ្ញើមានសិទ្ធិទាមទារកម្រៃពី អ្នកផ្ញើតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យា។ ក្នុងករណីអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ ក៏អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបានដែរ[55]។

**ឧទាហរណ៍៖** លោក "ក" និងលោក "ខ" គឺជាមិត្តនិងគ្នា លោក "ខ" តែងតែយកទំនិញមកផ្ញើនៅឃ្លាំងទទួលបញ្ញើរបស់លោក "ក" ដោយចុះកិច្ចសន្យាយកកម្រៃ។ ថ្ងៃមួយអ្នកទាំងពីរបានចុះកិច្ចសន្យាបញ្ញើប៉ុន្តែនៅក្នុងកិច្ចសន្យានោះមិនបានកំណត់តម្លៃចំពោះការរក្សាទុកឡើយ។ ក្នុងករណីនេះលោក "ក" អាចទាមទារកម្រៃសមរម្យពីលោក "ខ" បាន។

**ខ. សិទ្ធិសងវត្ថុបញ្ញើនៅពេលណាក៏បាន(ករណីពុំមានកំណត់ពេលសង)**

នៅក្នុងកិច្ចសន្យាបញ្ញើ ជាទូទៅពេលកំណត់ត្រូវសងត្រូវបានកំណត់ ដើម្បីជាប្រយោជន៍របស់អ្នកផ្ញើ។ មានន័យថា អ្នកផ្ញើរំពឹងថា អ្នកទទួលបញ្ញើនឹងរក្សាទុកវត្ថុបញ្ញើរហូតដល់ពេលកំណត់ត្រូវសង។ ដើម្បីការពារនូវការរំពឹងទុកនោះ មាត្រា ៦៨១ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា នៅពេលមានការកំណត់អំពីពេលត្រូវសងវត្ថុវិញ ជាគោលការណ៍ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានទេ។ ប៉ុន្តែអ្នកទទួលបញ្ញើ អាចសងវត្ថុបញ្ញើមុនពេលកំណត់បាន ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបានដូចជា ការរក្សាទុក មិនអាចធ្វើទៅបានដោយសារការខូចខាតសម្ភារៈសម្រាប់ស្តុកទុកនៅកន្លែងផ្ញើ ជាដើម។

ប្រសិនបើ ភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន[56]។ បើពេលសម្រាប់សងមិនត្រូវបានកំណត់ទេ វាមិនច្បាស់ទេថា អ្នកផ្ញើចង់ឱ្យអ្នកទទួលបញ្ញើរក្សាទុកវត្ថុបញ្ញើរហូតដល់ពេលណានោះទេ។ ដូច្នោះ ផលប្រយោជន៍របស់អ្នកផ្ញើនឹងមិនត្រូវបានធ្វើឱ្យខូចខាតច្រើនទេ ប្រសិនអ្នកទទួលបញ្ញើអាចសងវត្ថុនៅពេលណាក៏បាន។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាមិនបានកំណត់ពេលថាត្រូវសងវត្ថុបញ្ញើពេលណាទេ អ្នកទទួលបញ្ញើអាចសងពេលណាក៏បាន។

[55] សូមមើលមាត្រា ៦៦៩ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[56] មាត្រា៦៨១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**គ. សិទ្ធិទាមទារសំណងដែលបណ្តាលមកពីវត្ថុបញ្ញើដែលមិនមែនជាកំហុសរបស់ខ្លួន**

ប្រសិនបើអ្នកទទួលបញ្ញើ ទទួលរងការខូចខាតដោយសារ វត្ថុបញ្ញើដោយមិនមែនមកពីកំហុសរបស់អ្នកទទួលបញ្ញើ វាជាការសមស្របនឹងសមភាពដែលអ្នកផ្ញើ ត្រូវសងសំណងការខូចខាតនោះទៅ អ្នកទទួលបញ្ញើ។ អ្នកទទួលបញ្ញើ អាចទាមទារសំណងនៃការខូចខាតដែលបណ្តាលមកពីវត្ថុបញ្ញើដោយមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន ពីអ្នកផ្ញើបាន[57]។ **ឧទាហរណ៍៖** ប្រសិនបើផ្ទះរបស់អ្នកទទួលបញ្ញើ ត្រូវបានបំផ្លិចបំផ្លាញដោយសារការផ្ទុះវត្ថុបញ្ញើ អ្នកផ្ញើត្រូវទទួលបន្ទុកនូវការខូចខាតនោះ។ អ្នកផ្ញើត្រូវសងសំណងនៃការខូចខាតនោះនៅពេលដែលការខូចខាតនោះបានកើតឡើង។

**ឃ. សិទ្ធិឃាត់ទុក**

បើអ្នកកាន់កាប់វត្ថុរបស់អ្នកដ៏ទៃ មានសិទ្ធិលើបំណុលដែលបានកើតឡើង ដោយទាក់ទងនឹងវត្ថុនោះ អ្នកនោះអាចឃាត់ទុកនូវវត្ថុនោះបានរហូតដល់ពេលដែលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុល។ ប៉ុន្តែសិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសង[58]។ ចំពោះកិច្ច-សន្យាបញ្ញើ អ្នកទទួលបញ្ញើ អាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និងសំណងនៃការខូចខាត[59]។

**កថាភាគទី២៖ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ**

នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ អ្នកទទួលបញ្ញើមានករណីយកិច្ចដូចខាងក្រោម៖

**ក. រក្សាទុកវត្ថុបញ្ញើ**

អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើ មិនអាចប្រើវត្ថុបញ្ញើបានឡើយ[60]។ ដោយឡែកនៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ មាត្រា១២៥២ បានចែងថាបើផ្ញើឥតឱ្យឈ្នួល គេអាចសន្និដ្ឋានបានថាអ្នកផ្ញើបើក ឱ្យអ្នកទទួលបញ្ញើប្រើប្រាស់នូវវត្ថុដែលផ្ញើនោះបាន តែបើផ្ញើមានឈ្នួល គេមិនគប្បីសន្និដ្ឋានដូច្នោះឡើយ។ មានន័យថានៅក្នុងបញ្ញើយកកម្រៃ អ្នកផ្ញើមិនត្រូវបានសន្មតឱ្យប្រើវត្ថុបញ្ញើឡើយ។

**ខ. សងការខូចខាត**

អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើឱ្យបានល្អមិនឱ្យបាត់បង់ ឬខូចខាតឡើយ ក្នុងករណី

[57] មាត្រា៦៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មើលមាត្រា ៧៧៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[59] សូមមើលមាត្រា ៦៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[60] មាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អ្នកទទួលបញ្ញើបានធ្វើឱ្យបាត់បង់ ឬខូចខាតវត្ថុបញ្ញើ នោះអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត ដូចដែលបានចែងក្នុងក្រមរដ្ឋប្បវេណីមាត្រា ៦៧៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ អ្នកទទួលបញ្ញើនៅក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើ ត្រូវសងសំណងនៃការខូចខាតនោះ។ ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើក្នុងការសងសំណងនៃការខូចខាត គឺជាការទទួលខុសត្រូវដោយមានកំហុស ប៉ុន្តែអ្នកទាមទារសំណងនៃការខូចខាត មិនទទួលបន្ទុកក្នុងការបញ្ជាក់អំពីកំហុសនោះទេ។ម៉្យាងទៀត ការបាត់បង់រួមមានទាំងចោរកម្ម និង ការបាត់[61]។

**ឧទាហរណ៍៖** លោក "ក" បានទទួលបញ្ញើម៉ូតូដោយយកកម្រៃ ក្រោយមកលោក "ក" បានធ្វើឱ្យបាត់ម៉ូតូនោះ។ ក្នុងករណីនេះលោក "ក" ត្រូវសងសំណងនៃការខូចខាត។

### គ. ករណីយកិច្ចជូនដំណឹង

ប្រសិនបើតតិយជនបានអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះទៅឱ្យអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ[62]។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថា តតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថា កម្មសិទ្ធិរបស់អ្នកផ្ញើមានសុពលភាព ហើយផ្តល់ភស្តុតាងនោះទៅអ្នកទទួលបញ្ញើ ដើម្បីឱ្យអ្នកទទួលបញ្ញើធ្វើសកម្មភាពបណ្ដឹង ជាអាទិ៍ ដើម្បីផលប្រយោជន៍របស់អ្នកទទួលបញ្ញើ។

### ឃ. ករណីយកិច្ចសងវត្ថុដដែល(ដែលបានទទួល)

អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ[63]។

**ឧទាហរណ៍ ៖** លោក "ឃ" បានព្រមព្រៀងផ្ញើម៉ូតូហុងដាឌ្រីម ២០២០ ជាមួយអ្នកនាង "ខ" ដោយបង់កម្រៃ។ ដល់ពេលកំណត់ត្រូវសងវត្ថុអ្នកនាង "ខ" ត្រូវសងម៉ូតូហុងដាឌ្រីម២០២០របស់លោក "ឃ" ឱ្យទៅលោក "ឃ" វិញ។

### ង. សងវត្ថុដែលបានធ្វើឧបាទេសកម្ម

នៅក្នុងករណីដែលអ្នកទទួលបញ្ញើ ពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់វត្ថុបញ្ញើទេ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬវត្ថុផ្សេងទៀត ជំនួសវត្ថុបញ្ញើដែលត្រូវបានធ្វើឱ្យបាត់បង់ ឬបែកបាក់នោះអ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុដែលបានធ្វើឧបាទេសកម្មនោះ ឱ្យទៅអ្នកផ្ញើវិញ[64]។

[61] សេចក្តីកំណត់ក្រមរដ្ឋប្បវេណី គន្លឹះទី៥ ទំព័រទី១១៩

[62] មាត្រា ៦៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[63] មាត្រា ៦៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[64] មាត្រា ៦៨២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ឧទាហរណ៍៖** ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង អ្នកទទួលបញ្ញើត្រូវប្រគល់ប្រាក់ធានារ៉ាប់រងនោះទៅឱ្យអ្នកផ្ញើ។ បើនិយាយឱ្យតឹងរ៉ឹងទៅ ប្រសិនបើអ្នកទទួលបញ្ញើមានការធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងករណីដែលអ្នកទទួលបញ្ញើ មិនត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ប្រាក់ធានារ៉ាប់រងមិនត្រូវបានបង់ទៅអ្នកទទួលបញ្ញើទេ។ ក្នុងករណីនៃការធានារ៉ាប់រងចំពោះការខូចខាត ដោយសារកម្មសិទ្ធិករគួរតែបង្កើតកិច្ចសន្យាធានារ៉ាប់រង ជាទូទៅគ្មានប្រាប់ធានារ៉ាប់រងណាមួយនឹងត្រូវបានបង់ទៅឱ្យអ្នកទទួលបញ្ញើទេ។ ប៉ុន្តែដោយសារអាចមានករណីដែល អ្នកទទួលបញ្ញើដែលមិនមានកម្មសិទ្ធិ បង្កើតកិច្ចសន្យាធានារ៉ាប់រងយ៉ាងទូលំទូលាយលើហានិភ័យទូទៅ ប្រសិនបើអ្នកទទួលបញ្ញើ បានបង្កើតកិច្ចសន្យាបែបនេះ អ្នកទទួលបញ្ញើអាចទទួលប្រាក់ធានារ៉ាប់រង តាមខ្លឹមសារនៃកិច្ចសន្យាធានារ៉ាប់រងនោះបាន។ ក្នុងករណីនេះអ្នកទទួលបញ្ញើ ត្រូវប្រគល់ប្រាក់ធានារ៉ាប់រងនោះទៅអ្នកផ្ញើ។ ប្រសិនបើវត្ថុបញ្ញើត្រូវបានធ្វើឱ្យខូចខាតបណ្ដាលមកពីអំពើអនីត្យានុកូលរបស់តតិយជន សិទ្ធិទាមទារសំណងនៃការខូចខាត គឺមិនមែនជារបស់អ្នកទទួលបញ្ញើទេ ប៉ុន្តែជារបស់ម្ចាស់វត្ថុបញ្ញើ។ ដូច្នេះអ្នកទទួលបញ្ញើមិនត្រូវទទួលសំណងការខូចខាតឡើយ។ ប៉ុន្តែ មានករណីខ្លះដែលតតិយជននោះមិនដឹងថា កម្មសិទ្ធិករនៅឯណាហើយសងសំណងការខូចខាតនេះ ទៅអ្នកទទួលបញ្ញើបាន ដើម្បីឱ្យអ្នកទទួលបញ្ញើប្រគល់សំណងការខូចខាតនោះទៅអ្នកផ្ញើ។ ក្នុងករណីនេះ អ្នកទទួលបញ្ញើត្រូវប្រគល់នូវសំណងការខូចខាតដែលខ្លួនបានទទួលនោះទៅអ្នកផ្ញើ។

### ច. ប្រគល់ផល និងចំណូលពីវត្ថុបញ្ញើទៅអ្នកផ្ញើ

ករណីដែលបានទទួលផល ឬ ចំណូលដែលកើតឡើងពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើ ត្រូវប្រគល់ផល ឬ ចំណូលនោះឱ្យទៅអ្នកផ្ញើ[65]។ **ឧទាហរណ៍** មួយចំនួននៃផលដូចជា កូនសត្វដែលកើតចេញពីសត្វដែលត្រូវបានផ្ញើ និងផលចំណេញដែលបានមកពី អចលនវត្ថុដែលត្រូវបានផ្ញើ ( ដូចជាផលចំណេញបានមកពីកន្លែងចតរថយន្តដែលបានដាក់បញ្ញើ )។ ប៉ុន្តែដោយសារសត្វត្រូវការការថែទាំ វាមានការលំបាកក្នុងការយកសត្វមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើដោយគ្រាន់តែដើម្បី រក្សាទុក វត្ថុ។ តាមការជាក់ស្ដែងកិច្ចសន្យាអាណត្តិ នឹងត្រូវបានប្រើប្រាស់សម្រាប់ការរក្សាទុកសត្វ។ ករណីផលកើតចេញពីអចលនវត្ថុក៏មិនខុសគ្នាដែរ គឺកិច្ចសន្យាអាណត្តិដែលចែងអំពីការគ្រប់គ្រងជាវិជ្ជមាន ត្រូវបានប្រើញឹមញាប់ជាងកិច្ចសន្យាបញ្ញើ ដែលមានគោលបំណងត្រឹមតែដើម្បីរក្សាទុកវត្ថុប៉ុណ្ណោះ។

### ឆ. សោហ៊ុយនៃការសងវត្ថុបញ្ញើ

បញ្ញើ គឺជាកិច្ចសន្យាដែលមានខ្លឹមសារគ្រាន់តែរក្សាទុកវត្ថុបញ្ញើប៉ុណ្ណោះ ដូច្នោះ វាជាការសមរម្យក្នុងការសងវត្ថុបញ្ញើនៅទីកន្លែងដែលវត្ថុនោះបានរក្សាទុក ពីព្រោះថាប្រសិនបើអ្នកទទួលបញ្ញើត្រូវសងវត្ថុបញ្ញើនៅកន្លែង

[65] មាត្រា ៦៨៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្សេងពីកន្លែងដែលវត្ថុនោះត្រូវបានរក្សាទុកហានិភ័យនឹងកើតឡើងនៅពេលអ្នកទទួលបញ្ញើសងវត្ថុ ( **ឧទាហរណ៍** ការបាត់បង់ ឬ ការខូចខាត ក្នុងពេលដឹកជញ្ជូន ) ដែលធ្វើឱ្យបន្ទុករបស់អ្នកទទួលបញ្ញើនឹងកើនឡើង។ ហេតុដូច្នេះហើយ ជាគោលការណ៍ អ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុបញ្ញើទៅឱ្យអ្នកផ្ញើនៅទីកន្លែងដែលវត្ថុបញ្ញើបានរក្សាទុក ជាធម្មតាសោហ៊ុយសម្រាប់ការសងពុំកើតមានទេ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកទទួលបញ្ញើត្រូវសងនៅទីកន្លែងផ្សេងពីកន្លែងដែលវត្ថុបញ្ញើត្រូវបានរក្សាទុក ជាទូទៅ សោហ៊ុយសម្រាប់ការសង នឹងកើតមានឡើង ( **ឧទាហរណ៍ ៖** សោហ៊ុយក្នុងការដឹកជញ្ជូន )។ សួរថា តើអ្នកណាទទួលបន្ទុកលើសោហ៊ុយដែលត្រូវចំណាយសម្រាប់ ការសងវិញនូវវត្ថុបញ្ញើ? ជាគោលការណ៍សោហ៊ុយនៃការសង គឺជាបន្ទុករបស់កូនបំណុល[66] មានន័យថាជាបន្ទុករបស់អ្នកទទួលបញ្ញើ។ ដូច្នោះចំពោះបញ្ញើដោយយកកម្រៃ សោហ៊ុយសម្រាប់ការសងគឺជាបន្ទុករបស់អ្នកទទួលបញ្ញើ ។

**កថាភាគទី៣៖ ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ**

ជាទូទៅ នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ គឺអ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវបានទេ ព្រោះកិច្ចសន្យានេះ ជាកិច្ចសន្យាដែលចងកាតព្វកិច្ចរវាងភាគីទាំងសងខាង ហើយភាគីទាំងសងខាងមានសិទ្ធិ និងករណីយកិច្ចរៀងៗខ្លួន ហេតុនេះហើយបានជាមិនអាចរួចផុតពីការទទួលខុសត្រូវបាន ប៉ុន្តែ បើយើងគិតដល់ក្នុងករណីប្រធានសក្តិវិញ គឺអាចរួចផុតពីការទទួលខុសត្រូវបានព្រោះនៅក្នុងករណីនេះគឺយើងមិនអាចដឹងមុនថានឹងមានអ្វីកើតឡើងនៅពេលអនាគតបានទេ ហេតុនេះបានជាអាចរួចផុតពីការទទួលខុសត្រូវ[67]។

**ឧទាហរណ៍ទី១៖** លោក A បានផ្ញើទំនិញ នៅក្នុងឃ្លាំងផ្ញើទំនិញរបស់លោក B ដោយសារគ្រោះទឹកជំនន់ខ្លាំងបានធ្វើឱ្យលិចឃ្លាំងផ្ទុកទំនិញដែលបានធ្វើឱ្យទំនិញរបស់ A ខូចខាតយ៉ាងច្រើន។ ដោយសារតែគ្រោះទឹកជំនន់មិនបានដឹងមុន ហើយក៏មិនមានសេចក្តីប្រកាសជាមុន ដែលជាហេតុធ្វើឱ្យលោក B គាត់មិនបានត្រៀមទុកមុន។ ក្នុងករណីនេះគាត់អាចរួចផុតពីការទទួលខុសត្រូវ ព្រោះមិនមែនជាកំហុសរបស់គាត់។

ប្រសិនបើកើតឡើងដោយសារតែកំហុសរបស់អ្នកផ្ញើវិញ គឺអ្នកទទួលបញ្ញើមិនទទួលខុសត្រូវទេ។

**ឧទាហរណ៍ទី២៖** បើអ្នកផ្ញើធ្វើឱ្យបាត់នូវលិខិត ដែលបញ្ជាក់ថាខ្លួនបានផ្ញើវត្ថុនោះ នៅនឹងអ្នកទទួលបញ្ញើ។ បន្ទាប់មកមានអ្នករើសបានយកលិខិតនោះមកយកវត្ថុនោះទៅ។ ក្នុងករណីនេះអ្នកទទួលបញ្ញើមិនទទួលខុសទេ ព្រោះអ្នកផ្ញើមានការធ្វេសប្រហែសដោយខ្លួនឯង។

ក្នុងករណីដែលអ្នកផ្ញើឱ្យគេមកយកជំនួស ហើយបានប្រាប់ទៅអ្នកទទួលបញ្ញើថាប្រគល់វត្ថុដែលផ្ញើនោះឱ្យទៅអ្នកមកយកជំនួសទៅ ព្រោះគាត់ ( អ្នកផ្ញើ ) បានឱ្យគេមកយកជំនួស ក្នុងករណីនេះដែលប្រសិនជាអ្នក

[66] សូមមើលមាត្រា ៨៤៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[67] សូមមើលមាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មកយកជំនួសគាត់ មិនបានយកវត្ថុផ្ញើនោះទៅឱ្យ អ្នកផ្ញើទេបែរជាយកទៅផ្ញើអ្វីផ្សេង នោះអ្នកទទួលបញ្ញើមិនទទួលខុសត្រូវទេ ព្រោះអ្នកផ្ញើជាអ្នកឱ្យគាត់(អ្នកទទួលបញ្ញើ)ប្រគល់វត្ថុនោះទៅឱ្យអ្នកមកយកជំនួស។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ″ កិច្ចសន្យាបញ្ញើ ″ រួចមក យើងអាចសន្និដ្ឋានបានថាកិច្ចសន្យាបញ្ញើមួយនេះ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះជីវភាពប្រចាំថ្ងៃ ហើយមនុស្សភាគច្រើនគេមិនដឹងថាការផ្ញើបែបនេះគេហៅថាជាកិច្ចសន្យាបញ្ញើនោះទេ គឺគ្រាន់តែអ្នកខ្លះយកការផ្ញើមកប្រកបមុខរបរ ឯអ្នកខ្លះទៀតគ្រាន់តែជាការយកអាសារគ្នាទៅវិញទៅមកតែប៉ុណ្ណោះ តែបើគិតក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ កិច្ចសន្យាមួយនេះគឺជាកិច្ចសន្យាដែលមានចំណងគតិយុត្តរវាងអ្នកផ្ញើនិងអ្នកទទួលបញ្ញើ។ ក្នុងការបង្កើតកិច្ចសន្យានេះគឺមានបញ្ញើដោយយកកម្រៃ និង មិនយកកម្រៃ។ បញ្ញើយកកម្រៃជាកិច្ចសន្យាដែលចងកាតព្វកិច្ចរវាងអ្នកផ្ញើនិងអ្នកទទួលបញ្ញើក្រោយពីបញ្ចប់កិច្ចសន្យាគឺអ្នកផ្ញើមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ឯបញ្ញើមិនយកកម្រៃជាកិច្ចសន្យាដែលភាគីម្ខាងជាអ្នកខាត ភាគីម្ខាងទៀតជាអ្នកចំណេញ ហើយកិច្ចសន្យាអាចកើតឡើងបានដោយមានការប្រគល់វត្ថុ បើមិនមានការប្រគល់វត្ថុក៏កិច្ចសន្យានេះមិនអាចកើតឡើងបានទេ ក្រោយពីបញ្ចប់កិច្ចសន្យាអ្នកទទួលបញ្ញើត្រូវប្រគល់វត្ថុឱ្យអ្នកផ្ញើវិញ ហើយអ្នកផ្ញើមិនមានករណីយកិច្ចអ្វីទាំងអស់ តែប្រសិនជាកិច្ចសន្យាមួយនេះប្រែក្លាយ ជាកិច្ចសន្យាអមញ្ញៈវិញអ្នកផ្ញើ គឺមានករណីយកិច្ចបង់ប្រាក់ឱ្យ អ្នកទទួលបញ្ញើព្រោះអ្នកទទួលបញ្ញើបានរងព្យសនកម្ម។

ដូច្នេះអ្នកទទួលបញ្ញើ ត្រូវតែបំពេញកិច្ចការដោយយកចិត្តទុកដាក់ ដោយការរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជា អ្នកគ្រប់គ្រងដោយសុចរិត។ ប្រសិនបើបានធ្វើឱ្យខូចខាតចំពោះវត្ថុបញ្ញើនោះអ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវសងការខូចខាត ប៉ុន្តែប្រសិនបើការខូចខាតដោយការតែករណីប្រធានសក្តិវិញនោះអ្នកទទួលបញ្ញើអាចរួចផុតពីការទទួលខុសត្រូវបាន។ លើសពីនេះអ្នកទទួលបញ្ញើត្រូវជូនដំណឹងក្នុងករណីដែលមានតតិយជនបានដាក់ពាក្យបណ្តឹងអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ ទៅអ្នកផ្ញើឱ្យបានដឹង។ ហើយនៅពេលដល់ពេលសងវត្ថុអ្នកទទួលបញ្ញើត្រូវសងវត្ថុដដែលដែលបានទទួលពីអ្នកផ្ញើ។

ចំពោះអ្នកផ្ញើ មានករណីយកិច្ចបង់កម្រៃចំពោះបញ្ញើយកកម្រៃ សោហ៊ុយ និងសំណងការខូចខាតជូនអ្នកទទួលបញ្ញើដែលបានកើតឡើងក្នុងអំឡុងពេល រក្សាទុកវត្ថុបញ្ញើ។ កិច្ចសន្យាបញ្ញើ នឹងត្រូវបានបញ្ចប់នៅពេលដែលអ្នកទទួលបញ្ញើប្រគល់វត្ថុទៅឱ្យអ្នកផ្ញើវិញ។

សរុបសេចក្តីមក កិច្ចសន្យាបញ្ញើ ជាកិច្ចសន្យាដែលអ្នកផ្ញើ មានឆន្ទៈផ្ទេរបន្ទុកហានិភ័យទៅអ្នកទទួលបញ្ញើ ដោយការផ្ទេរការកាន់កាប់។ អ្នកទទួលបញ្ញើ មានឆន្ទៈទទួលយកបន្ទុកហានិភ័យដោយរក្សាទុក វត្ថុបញ្ញើដើម្បីប្រយោជន៍របស់អ្នកផ្ញើ។ ប្រសិនបើអ្នកទទួលបញ្ញើបានធ្វើឱ្យខូចខាតដល់វត្ថុបញ្ញើ ត្រូវទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន តាមរយៈការសងសំណងទៅភាគីម្ខាងទៀត។ ក្រោយពីពួកគេបានបង្កើតកិច្ចសន្យាបញ្ញើនេះ

ឡើង ដែលនាំឱ្យសិទ្ធិ និង ករណីយកិច្ចរបស់ពួកគេត្រូវបានបង្កើតឡើងដែលត្រូវតែទទួលខុសត្រូវ។ ការជឿទុកចិត្ត និងទំនាក់ទំនងល្អនាំឱ្យកើតមានកិច្ចសន្យាបញ្ញើ យកកម្រៃ ឬមិនយកកម្រៃ គឺអាស្រ័យទៅលើអ្នកទទួលបញ្ញើថាយកកម្រៃ ឬមិនយក។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការស្រាវជ្រាវ និងការតាក់តែងអត្ថបទសារណាទៅលើប្រធានបទ កិច្ចសន្យាបញ្ញើរួចមក យើងខ្ញុំសូមផ្តល់អនុសាសន៍ក្នុងន័យកែលំអរ ដើម្បីជាប្រយោជន៍ដល់ការអនុវត្តន៍កិច្ចសន្យានិងដើម្បីជៀសវាងកុំអោយមានវិវាទ។ ដូចនេះយើងខ្ញុំសូមផ្តល់ជាអនុសាសន៍ដូចខាងក្រោមៈ

- សិទ្ធិ និង ករណីយកិច្ចរបស់អ្នកទទួលបញ្ញើនិងអ្នកផ្ញើ ចែងមកមានការពិបាកក្នុងការវែកញែកថាវាមាននៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ ឬមិនយកកម្រៃដោយសារតែមានចែងក្នុងបញ្ញត្តិតែមួយ។ ប្រសិនជាមានការបែងចែកឱ្យដាក់ពីគ្នាគឺវាមានភាពងាយស្រួលក្នុងការកំណត់ជាងនេះ។
- នៅក្នុងកិច្ចសន្យាបញ្ញើ ក្រមរដ្ឋប្បវេណីមិនបានបញ្ជាក់អោយបានច្បាស់លាស់ថាតើស្ថានភាពបែបណាដែលចាត់ទុកថាមានការផ្ទេរការកាន់កាប់ ដែលជាហេតុធ្វើអោយមាន ការភាន់ច្រឡំជាមួយការជួលចំណត។ ហេតុនេះហើយប្រសិនបើ ក្រមចែងអំពីស្ថានភាពដែលចាត់ទុកថា មានការផ្ទេការកាន់កាប់ (ដូចជាការប្រគល់សោរចំពោះរថយន្ត និងគ្រឿងយន្តធំៗផ្សេងៗទៀត ដែលត្រូវគ្រប់គ្រងដោយប្រើប្រាស់សោរ ឬឧបករណ៍បញ្ជា ចំពោះវត្ថុ យានជំនិះផ្សេងៗដែលអាចបំលាស់ទីបានដោយងាយស្រួល ដោយមិនប្រើ ឬពុំចាំបាច់ប្រើសោរ ឬឧបករណ៍បញ្ជា ឧទាហរណ៍ កង់ ម៉ូតូ... ) នោះធ្វើអោយអ្នកផ្ញើមិនមានការភាន់ច្រឡំ និងងាយស្រួលក្នុងការអនុវត្តន៍កិច្ចសន្យានិងជៀសវាងមានវិវាទនៅពេលបាត់កម្មវត្ថុនៃបញ្ញើ។
- នៅក្នុងកិច្ចសន្យាបញ្ញើយកកម្រៃ មិនបានចែងថាតើលក្ខណៈបែបណាដែលចាត់ទុកថា ជាលក្ខណៈនៃការទទួលយកដើម្បីរក្សាទុកវត្ថុបញ្ញើ ដើម្បីឱ្យអ្នកផ្ញើមានជំនឿទុកចិត្តក្នុងការផ្ញើព្រោះវា គឺជាបញ្ញើយកកម្រៃដែលអ្នកផ្ញើ ត្រូវបង់កម្រៃទៅអ្នកទទួលបញ្ញើតាមការព្រមព្រៀង។ ប្រសិនវាបានចែងច្បាស់លាស់អំពីលក្ខណៈនៃការទទួលយកដើម្បីរក្សាទុកវត្ថុបញ្ញើ ( កន្លែងផ្ញើត្រូវមានទ្វារច្រកចេញចូល បិទ បើក និងរបងហ៊ុំព័ទ្ធធានាសុវត្ថិភាពបានគ្រប់គ្រាន់ មានសន្តិសុខយាម និងត្រួតពិនិត្យការយកចូលនិងយកចេញប្រើប្រាស់សំបុត្រផ្ញើ ឬលិខិតបញ្ជាក់ផ្សេងៗ ដើម្បីសំគាល់អត្តសញ្ញាណនៃវត្ថុបញ្ញើជាមួយអ្នកផ្ញើ....) នោះវាអាចធានានូវសុវត្ថិភាព និងផ្តល់ទំនុកចិត្តជូនអ្នកផ្ញើឱ្យបានកាន់តែល្អច្រើនជាងមុនទៀត។
- ម្យ៉ាងវិញទៀត បញ្ញត្តិនៃមាត្រា ៦៧៤ មិនបានចែងឱ្យបានច្បាស់ចំពោះការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើថាតើចំពោះបញ្ញើយកកម្រៃឬបញ្ញើមិនយកកម្រៃ ដើម្បីងាយស្រួលក្នុងការអនុវត្តន៍កិច្ចសន្យានៅក្នុងជីវភាពប្រចាំថ្ងៃ ក្នុងករណីធ្វើឱ្យបាត់បង់ ឬ បែកបាក់ អ្នកទទួលបញ្ញើត្រូវសងការខូចខាតប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តន៍ឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុស ចំពោះការ

ធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ។ ក្នុងបញ្ញត្តិនេះផងដែរយើងឃើញថាមិនមានការបញ្ជាក់ថា តើចំពោះបញ្ញើយកកម្រៃ ឬ មិនយកកម្រៃ ឬ យ៉ាងណា។ នៅក្នុងកថាខណ្ឌទី២ និង ទី៣ នៃមាត្រា ដដែលនេះក៏ដូចគ្នាឃើញថាមិនមានការបញ្ជាក់ថាចំពោះបញ្ញើយកម្រៃ ឬ មិនយកកម្រៃឡើយ។

ដូច្នេះ យើងខ្ញុំសង្ឃឹមថាក្រមរដ្ឋប្បវេណី និងបញ្ញត្តិឱ្យបានច្បាស់លាស់ថាតើបញ្ញត្តិណាអនុវត្តន៍ចំពោះបញ្ញើយកកម្រៃ និងបញ្ញត្តិណាអនុវត្តន៍ចំពោះបញ្ញើមិនយកកម្រៃដើម្បីងាយស្រួលនៅក្នុងការអនុវត្តន៍។

# ឯកសារយោង

## បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណី ជប៉ុន
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៣ គន្ថីទី ៥ ឆ្នាំ២០១០
- សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១ - ៣ ឆ្នាំ២០១៧
- ក្រឹត្យ ច្បាប់ ស្ដីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

## សៀវភៅ

- មួន សៀងលី កម្រងបទបង្ហាញច្បាប់ ស្ដីពី នីតិរដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១៩
- អ៊ីវ ប៉ូលី កិច្ចសន្យា   ២១.១២.២០១១
- យស បានចំរុង ខាំ សុមករា នីតិកិច្ចសន្យាពិសេស  ឆ្នាំ២០១៣
- អៀង សំណាង កិច្ចសន្យាពិសេស ភាគ ២ ឆ្នាំ២០១៨
- ញ៉ឹក វុធ្ធី នីតិកាតព្វកិច្ច ភាគ ១ និង ភាគ២

## សន្ទានុក្រម

- សន្ទានុក្រម នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៦៦៧.–** ភាពផ្ទាល់មុខលើបុគ្គល នៃកិច្ចសន្យាការងារ

១-បើគ្មានការយល់ព្រមពីកម្មករនិយោជិតទេ និយោជកពុំអាចធ្វើអនុប្បទានសិទ្ធិនោះ ឱ្យទៅតតិយជនបានឡើយ ។

២-បើគ្មានការយល់ព្រមពីនិយោជកទេ កម្មករនិយោជិត ពុំអាចឱ្យតតិយជនធ្វើពលកម្មជំនួសខ្លួនបានឡើយ ។

៣-ប្រសិនបើភាគីណាមួយនៃកិច្ចសន្យាការងារ បានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យានោះបាន ។

**មាត្រា ៦៦៨.–** ការអនុវត្តច្បាប់ការងារ

ចំពោះកិច្ចសន្យាការងារ ក្រៅពីបញ្ញត្តិដែលកំណត់នៅក្នុងក្រមនេះ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃច្បាប់ការងារ ។

# ជំពូកទី ១០

# បញ្ញើ

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅស្តីពីបញ្ញើ

**មាត្រា ៦៦៩.–** និយមន័យនៃបញ្ញើ

១-បញ្ញើ សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះ ទៅឱ្យអ្នកផ្ញើវិញ ។

២-បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីយកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬ ប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើ

កិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យពីអ្នកផ្ញើបាន ។

**មាត្រា ៦៧០.–** ភាពចាំបាច់ក្នុងការទទួលយកវត្ថុនៃកិច្ចសន្យាបញ្ញើ

១-កិច្ចសន្យាបញ្ញើ ត្រូវបានបង្កើតឡើង ដោយអ្នកទទួលបញ្ញើ ទទួលយកកម្មវត្ថុនៃបញ្ញើ តាមការព្រមព្រៀង ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើបានកាន់កាប់កម្មវត្ថុនៃបញ្ញើនោះហើយ កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយការព្រមព្រៀងបង្កើតទំនាក់ទំនងបញ្ញើនោះ ។ ចំពោះវត្ថុដែលកាន់កាប់ដោយតតិយជន កិច្ចសន្យាបញ្ញើត្រូវបានបង្កើត នៅពេលដែលបានផ្ទេរការកាន់កាប់ដោយការបញ្ជា ។

**មាត្រា ៦៧១.–** អានុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀង

ប្រសិនបើភាគី គ្រាន់តែបានព្រមព្រៀងថា នឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗអាចដកការព្រមព្រៀងនោះចេញ នៅពេលណាក៏បាន រហូតដល់ពេលដែលបានប្រគល់កម្មវត្ថុនៃបញ្ញើនោះ ។ ប៉ុន្តែ ក្នុងករណីដែលបានសន្យាបង្កើតកិច្ចសន្យាបញ្ញើដោយឱ្យបង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតដល់ភាគីម្ខាងទៀត ដោយសារការបដិសេធមិនទទួលវត្ថុបញ្ញើផ្ទុយនឹងការសន្យានោះ ភាគីដែលជាអ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងសំណងនៃការខូចខាតនោះ ឱ្យទៅភាគីម្ខាងទៀត ប្រសិនបើការបដិសេធនោះ គ្មានមូលហេតុត្រឹមត្រូវទេ ។

**មាត្រា ៦៧២.–** កិច្ចសន្យាបញ្ញើដែលបានធ្វើដោយអ្នកគ្មានកម្មសិទ្ធិ

ទោះបីជាអ្នកផ្ញើគ្មានកម្មសិទ្ធិលើវត្ថុផ្ញើក៏ដោយ ក៏កិច្ចសន្យាបញ្ញើនោះ ត្រូវបានបង្កើតអានុភាពដែរ ។ នៅក្នុងករណីនេះ ទោះបីជាមានពាក្យបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករ ចំពោះអ្នកទទួលបញ្ញើក៏ដោយ ក៏អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះទៅឱ្យអ្នកផ្ញើវិញបានដែរ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករ ត្រូវបានទទួលស្គាល់ ។

**មាត្រា ៦៧៣.–** ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

២-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើ មិនអាចប្រើវត្ថុបញ្ញើបាន ឡើយ ។

**មាត្រា ៦៧៤.–** ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ

១-នៅក្នុងករណីដែលបានធ្វើឱ្យបាត់បង់ ឬ បានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើ ត្រូវសងសំណងនៃការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុស ចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ ។

២-ក្នុងករណីដែលបញ្ញើត្រូវបានធ្វើឡើង តាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវ ចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

៣-នៅទីកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិប្បកម្មផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិប្បកម្មទាំងឡាយនោះ បានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់បានឡើយ ។

**មាត្រា ៦៧៥.–** ការបន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកផ្ញើ ដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាង និង កាលៈទេសៈផ្សេងៗទៀតបាន ។

**មាត្រា ៦៧៦.-** ការសម្រាលការទទួលខុសត្រូវក្នុងករណីដែលមិនបានរាយការណ៍អំពីវត្ថុដែលមានតម្លៃខ្ពស់

នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និង វត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត ប្រសិនបើអ្នកផ្ញើ មិនបានរាយការណ៍អំពីប្រភេទ និង តម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការអាចបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន ។

**មាត្រា ៦៧៧.-** ករណីយកិច្ចនៃការរក្សាទុកដោយខ្លួនឯង

១-បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និង ត្រួតពិនិត្យអ្នកទទួលបញ្ញើដែលត្រូវបានឱ្យរក្សាទុកបន្ត ។

**មាត្រា ៦៧៨.-** បញ្ញើបន្ត

១-បញ្ញត្តិនៃជំពូកទី ១០ (បញ្ញើ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះទំនាក់ទំនងរវាងអ្នកទទួលបញ្ញើ និង អ្នកទទួលបញ្ញើបន្ត ។

២-អ្នកទទួលបញ្ញើបន្ត មានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងអ្នកទទួលបញ្ញើដែរចំពោះអ្នកផ្ញើ ។

៣-ក្នុងករណីដែលបានសងវត្ថុបញ្ញើឱ្យទៅអ្នកផ្ញើហើយ អ្នកទទួលបញ្ញើបន្ត ត្រូវរួចផុតពីករណីយកិច្ចសង ចំពោះអ្នកទទួលបញ្ញើ ។

**មាត្រា ៦៧៩.-** ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ

ប្រសិនបើតតិយជនដែលអះអាងអំពីសិទ្ធិចំពោះវត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬ វត្ថុបញ្ញើ ត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកផ្ញើ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ៦៨០.-** ការទាមទារឱ្យសង ពីអ្នកផ្ញើ

ទោះបីជាភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

**មាត្រា ៦៨១.-** ការសងពីអ្នកទទួលបញ្ញើ

១-ប្រសិនបើភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះ នៅពេលណាក៏បាន ។

២-ប្រសិនបើមានកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានឡើយ ។

**មាត្រា ៦៨២.-** អត្ថន័យនៃករណីយកិច្ចសង

១-អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ ។

២-នៅក្នុងករណីដែលអ្នកទទួលបញ្ញើ ពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬ បែកបាក់វត្ថុបញ្ញើទេ ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬ វត្ថុផ្សេងទៀត ជំនួសវត្ថុបញ្ញើដែលត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់នោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុដែលបានធ្វើឧបាទេសកម្មនោះ ឱ្យទៅអ្នកផ្ញើវិញ ។

**មាត្រា ៦៨៣.-** ការចាត់ចែងផល ជាអាទិ៍

ក្នុងករណីដែលបានទទួលផល ឬ ចំណូលដែលកើតឡើងពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើ ត្រូវប្រគល់ផល ឬ ចំណូលនោះ ឱ្យទៅអ្នកផ្ញើ ។

**មាត្រា ៦៨៤.-** បញ្ញើជាប្រាក់

១-ប្រសិនបើបានទទួលការផ្ញើជាប្រាក់ អ្នកទទួលបញ្ញើ ត្រូវរក្សាទុក តាមរបៀបដែលបានកំណត់ក្នុងកិច្ចសន្យា ។ នៅក្នុងករណីនេះ បើគ្មានការសន្យាជាពិសេសទេ អ្នកទទួលបញ្ញើ ពុំមានករណីយកិច្ចបង់ការប្រាក់ឡើយ ។

២-ក្នុងករណីដែលអ្នកទទួលបញ្ញើ អាចរក្សាទុកប្រាក់ ដោយដាក់ជាប្រាក់បញ្ញើក្នុងធនាគារ បញ្ញត្តិនៃមាត្រា ៦៨៣ (ការចាត់ចែងផល ជាអាទិ៍) ខាងលើនេះ ត្រូវយកមក

អនុវត្តផងដែរ ចំពោះការប្រាក់នោះ ។

**មាត្រា ៦៨៥.–** សោហ៊ុយនៃការសងវត្ថុបញ្ញើ

នៅក្នុងបញ្ញើដោយមិនយកកម្រៃ សោហ៊ុយចាំបាច់នៃការសងវត្ថុបញ្ញើ ត្រូវជាបន្ទុករបស់អ្នកផ្ញើ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកទទួលបញ្ញើ បានផ្លាស់ប្តូរកន្លែងផ្ញើ សោហ៊ុយនៃការសងវត្ថុបញ្ញើ ដែលកើនឡើងដោយសារការផ្លាស់ប្តូរកន្លែងនោះ ត្រូវជាបន្ទុករបស់អ្នកទទួលបញ្ញើ ។

**មាត្រា ៦៨៦.–** ករណីយកិច្ចសងសោហ៊ុយវិញ របស់អ្នកផ្ញើ

១-អ្នកផ្ញើ ចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ ក្នុងការរក្សាទុកវត្ថុបញ្ញើ ។

២-អ្នកទទួលបញ្ញើ អាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីវត្ថុបញ្ញើ ដោយមិនមែនជាកំហុសរបស់ខ្លួន ពីអ្នកផ្ញើបាន ។

**មាត្រា ៦៨៧.–** កន្លែងសង

ប្រសិនបើមិនបានកំណត់ក្នុងកិច្ចសន្យា ការសងវត្ថុបញ្ញើ ចាំបាច់ត្រូវធ្វើនៅកន្លែងដែលត្រូវរក្សាទុកវត្ថុបញ្ញើនោះ ។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើបានផ្លាស់ប្តូរកន្លែងរក្សាទុកវត្ថុនោះ ដោយមានមូលហេតុត្រឹមត្រូវ ការសងអាចធ្វើនៅកន្លែងរក្សាទុកជាក់ស្តែងនាពេលសងបាន ។

**មាត្រា ៦៨៨.–** សិទ្ធិឃាត់ទុក របស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើ អាចឃាត់ទុកវត្ថុបញ្ញើ រហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និង សំណងនៃការខូចខាត ដែលបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រា ៦៨៦ (ករណីយកិច្ចសងសោហ៊ុយវិញ របស់អ្នកផ្ញើ) នៃក្រមនេះ បាន ។

## ផ្នែកទី ២
## បញ្ញើដោយរួមបញ្ចូលគ្នា

**មាត្រា ៦៨៩.–** បញ្ញើដោយរួមបញ្ចូលគ្នា

ប្រសិនបើអ្នកទទួលបញ្ញើ ទទួលបញ្ញើ នូវវត្ថុដែលមានប្រភេទដូចគ្នា ពីអ្នកផ្ញើច្រើននាក់ ហើយអាចរក្សាទុករួមបញ្ចូលគ្នា ដោយមិនបាច់បែងចែកវត្ថុបញ្ញើនោះ តាមកិច្ចសន្យា អ្នកផ្ញើនីមួយៗ មានសិទ្ធិទៅតាមសមាមាត្រនៃចំនួនវត្ថុផ្ញើរបស់ខ្លួន ចំពោះវត្ថុទាំងមូល ដែលត្រូវបានរក្សាទុកដោយរួមបញ្ចូលគ្នា ។

## ផ្នែកទី ៣
## បញ្ញើបរិភោគ

**មាត្រា ៦៩០.–** បញ្ញើបរិភោគ

នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើ អាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើ មានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និង ចំនួនដូចគ្នានឹងវត្ថុបញ្ញើនោះ ។

**មាត្រា ៦៩១.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីការខ្ចីបរិភោគ

បញ្ញត្តិស្តីពីការខ្ចីបរិភោគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបញ្ញើបរិភោគដែលបានកំណត់នៅក្នុងមាត្រា ៦៩០ (បញ្ញើបរិភោគ) ខាងលើនេះ ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើគ្មានកំណត់អំឡុងពេលសងនៅក្នុងកិច្ចសន្យាទេ អ្នកផ្ញើអាចទាមទារឱ្យសង នៅពេលណាក៏បាន ។

# គំរូកិច្ចសន្យា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គំរូលិខិតទី ៣

*****

## កិច្ចសន្យាបញ្ជើរថយន្ត

រវាង

ឈ្មោះ.....................ភេទ...........អាយុ........អត្តសញ្ញាណប័ណ្ណលេខ.................អាស័យដ្ឋានផ្ទះលេខ..........ផ្លូវ.............ភូមិ.............សង្កាត់.......................ខណ្ឌ.............................ក្រុង.....................មុខរបរ.........................ត្រូវជាម្ចាស់កម្មសិទ្ធិករលើឡានម៉ាក.....................ពណ៌.................មានស្លាកលេខ.....................ចេញដោយចាប់ពីពេលនេះទៅហៅថា ភាគី "ក" ។ ទូរស័ព្ទលេខ...............................។

និង

ឈ្មោះ....................ភេទ..........អាយុ............អត្តសញ្ញាណប័ណ្ណលេខ.................អាស័យដ្ឋានផ្ទះលេខ..............ផ្លូវ.............ភូមិ.............សង្កាត់.....................ខណ្ឌ.............................ខេត្ត........................មុខរបរ.......................ចាប់ពីពេលនេះទៅហៅថា ភាគី "ខ" ។ ទូរស័ព្ទលេខ..........................។

### គូភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖

ប្រការ ១ ភាគី "ក" ស្នើសុំផ្ញើឡានដែលមានម៉ាក ពណ៌និងស្លាកលេខដូចខាងលើ ដែលជាកម្មសិទ្ធិរបស់ខ្លួនចំពោះ ភាគី "ខ" ។

ប្រការ ២ ភាគី "ខ" យល់ព្រមតាមសំណើរបស់ ភាគី "ក" ហើយ ភាគី "ក" បានប្រគល់ឡាន ដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើនោះ នៅថ្ងៃទី........ខែ..........ឆ្នាំ..........ទៅឱ្យភាគី "ខ" ដើម្បីរក្សាទុកក្នុងទីកន្លែងដែលបានព្រមព្រៀងគ្នា ។

ប្រការ ៣ រយៈពេលនៃការផ្ញើនេះមានចំនួន.................ដោយគិតចាប់ពី ថ្ងៃទី.........ខែ.......ឆ្នាំ.......ដល់ថ្ងៃទី.......ខែ.......ឆ្នាំ.......។

ប្រការ ៤ កម្រៃនៃការផ្ញើឡាននេះមានចំនួន..........................។ ហើយនៅថ្ងៃទី.........ខែ..........ឆ្នាំ..........ភាគី "ក" បានប្រគល់ប្រាក់កម្រៃចំនួន............................ឱ្យទៅភាគី "ខ" ដែលជាថ្នូរនឹងការបញ្ញើឡាននោះ ។

ប្រការ ៥ ការទទួលខុសត្រូវៈ ភាគី "ខ" ត្រូវមានករណីយកិច្ចរក្សានូវឡាននេះឱ្យបានល្អ ។ ករណីដែលភាគី "ខ" មានការធ្វេសប្រហែសបណ្តាល ឱ្យមានព្យសនកម្ម កើតឡើងជាហេតុធ្វើឡានទទួលរងនូវការខូចខាតនោះ ភាគី "ខ" ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតទាំងនោះ ត្រូវចេញសងសំណងការខូចខាតតាមករណីដែលបានកើតជាក់ស្តែង ។

កិច្ចសន្យានេះធ្វើឡើងដោយពិតប្រាកដនិងដោយសេរី មិនមាននូវការបង្ខិតបង្ខំ ឬការគំរាមកំហែងឡើយ គឺធ្វើឡើងដោយយើងខ្ញុំមានសតិ ស្មារតីគ្រប់គ្រាន់ហើយបានអានបានស្តាប់ត្រឹមត្រូវរួចហើយ ។

កិច្ចសន្យានេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃ ដែលយើងខ្ញុំបានផ្តិតមេដៃស្តាំទទួលយល់ព្រមតទៅ ។

ធ្វើនៅ.......... ថ្ងៃទី............ខែ.......ឆ្នាំ ២០១៨

សាក្សីទី១ សាក្សីទី ២ ស្នាមមេស្តាំដៃភាគី“ខ” ស្នាមមេដៃស្តាំភាគី“ក”

ឈ្មោះ...... ឈ្មោះ........ ឈ្មោះ.......... ឈ្មោះ...........

ស្នាមមេដៃ

N. 8806

**ប្រៃសណីយ៍ និង ទូរគមនាគមន៍កម្ពុជា**

**ប័ណ្ណផ្ញើកង់-ម៉ូតូ**

ប្រភេទ................ពណ៌................តំលៃ 1000R

ថ្ងៃទី 31 ខែ 5 ឆ្នាំ២០១7

ផុតកំណត់ពេលយាមត្រឹមម៉ោង 5h00

ហួសរយៈពេល ១ថ្ងៃ ទុកជាអសារបង់